ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងបរិស្ថាន

...........................

# សេចក្តីព្រាង
# ច្បាប់
# ស្តីពី
# ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**សេចក្តីព្រាង ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥**

# ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១._**

ច្បាប់នេះមានគោលដៅគាំពារបរិស្ថាន អភិរក្សប្រព័ន្ធអេកូឡូស៊ី ធានាឱ្យបាននូវការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព តាមរយៈការបង្កើតយន្តការនានា ដើម្បីវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលកើតចេញពីរាល់គម្រោងអភិវឌ្ឍន៍ ដែលអាចនឹងបង្កផលប៉ះពាល់ ដល់បរិស្ថាន សុខភាព សង្គម សេដ្ឋកិច្ច និងវប្បធម៌ ។

**មាត្រា ២._**

ច្បាប់នេះមានគោលបំណង៖

១-កំណត់ឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើគម្រោងអភិវឌ្ឍន៍ ទាំងសាធារណៈ និងឯកជន មុននឹងដាក់ជូនអង្គភាពមានសមត្ថកិច្ច ឬក្រសួងសាមី ឬ/និងរាជរដ្ឋាភិបាលសម្រេច ។

២-លើកកម្ពស់ការចូលរួមជាសាធារណៈ និងសិទ្ធិរបស់សាធារណជនគ្រប់រូប ក្នុងការទទួលបានព័ត៌មានស្តីពីគម្រោងអភិវឌ្ឍន៍ ដែលអាចបង្កផលប៉ះពាល់ ចំពោះបរិស្ថាន សុខភាព សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួន ។

៣-ធានាការអនុវត្តសកម្មភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ធ្វើឡើងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងសមធម៌សង្គម ។

៤-លើកកម្ពស់ប្រសិទ្ធភាពនៃការបង្កើត និងតាមដានការអនុវត្តវិធានការបង្ការ បញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ព្រមទាំងវិធានការជួសជុល ស្តារ ឬសំណងខូចខាតទាំងឡាយដែលបង្កឡើងដោយគម្រោងអភិវឌ្ឍន៍ ។

**មាត្រា ៣._**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះគម្រោងអភិវឌ្ឍន៍ ទាំងសាធារណៈ និងឯកជន ដែលជាគម្រោងស្នើសុំ គម្រោងមានស្រាប់ និងគម្រោងកំពុងដំណើរការនៅក្នុងទឹកដីព្រះរាជាណាចក្រកម្ពុជា។

ច្បាប់នេះក៏មានវិសាលភាពអនុវត្តចំពោះ រាល់គម្រោងអភិវឌ្ឍន៍ ដែលមិនទាន់បានសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយរាប់បញ្ចូលទាំងគម្រោងដែលទទួលបាន ឬពុំទាន់ទទួលបានលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ សេចក្តីសម្រេចពីក្រសួង ឬស្ថាប័នមានសមត្ថកិច្ចអនុម័តគម្រោង ។

ច្បាប់នេះក៏មានវិសាលភាពអនុវត្តផងដែរ ចំពោះគម្រោងអភិវឌ្ឍន៍ទាំងឡាយណាដែលអាចបង្កឱ្យមានផលប៉ះពាល់ឆ្លងដែនដល់បរិស្ថាន សុខភាព សេដ្ឋកិច្ច សង្គម និងវប្បធម៌ ល្គឹកណាមានការទទួលស្គាល់ពីកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី សន្ធិសញ្ញាអន្តរជាតិស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដែលព្រះរាជាណាចក្រកម្ពុជាជាហត្ថលេខី។

លក្ខណៈវិនិច្ឆ័យ និងចំណាត់ថ្នាក់ប្រភេទគម្រោង ដែលត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤._**

ច្បាប់នេះមិនអនុវត្តចំពោះគម្រោងអភិវឌ្ឍន៍ ឬសកម្មភាពរបស់រដ្ឋ ដែលបានអនុម័តដោយរាជរដ្ឋាភិបាល ឬរដ្ឋសភា ហើយដែលចាត់ទុកជាគម្រោងចាំបាច់ និងបន្ទាន់ទាក់ទងនឹងសន្តិសុខជាតិ បូរណភាពទឹកដី អធិបតេយ្យជាតិ ឬការគ្រប់គ្រងគ្រោះមហន្តរាយនានា ។

**មាត្រា ៥._**

និយមន័យនៃវាក្យស័ព្ទដែលប្រើក្នុងច្បាប់នេះ ត្រូវកំណត់នៅក្នុងសទ្ទានុក្រមនៃច្បាប់នេះ ។

# ជំពូកទី ២

# គោលការណ៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា ៦._**

រាល់គម្រោងអភិវឌ្ឍន៍ ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់ទៅលើបរិស្ថាន សេដ្ឋកិច្ច សង្គម សុខភាព និងវប្បធម៌ ដោយមានការឯកភាពពីក្រសួងបរិស្ថានជាមុនសិន មុននឹងបញ្ជូនទៅរាជរដ្ឋាភិបាលសម្រេច ។ អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬសេចក្តីសម្រេចនានាដែលផ្ទុយនឹងស្មារតីនៃបទប្បញ្ញត្តិនេះត្រូវទុកជាមោឃៈ ។

**មាត្រា ៧._**

កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នឹងយកជាការបាន លុះត្រាតែកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះ ធ្វើឡើងស្របតាមល័ក្ខខ័ណ្ឌនានាដែលបញ្ញត្តិទុកក្នុងច្បាប់នេះ ហើយធានាបានជានិច្ចកាលនូវការគោរពគោលការណ៍ជាអាទិ៍ដូចខាងក្រោម ៖

-រូបវន្តបុគ្គល នីតិបុគ្គលនៃនីតិសាធារណៈ នីតិបុគ្គលនៃនីតិឯកជន វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍ដែលទទួលរងផលប៉ះពាល់ពីគម្រោង មានសិទ្ធិទទួលបានព័ត៌មាន និងសិទ្ធិចូលរួមផ្តល់យោបល់ក្នុង កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អនុលោមតាមបែបបទ នីតិវិធី និងល័ក្ខខ័ណ្ឌដែលកំណត់ក្នុងជំពូក ៥ នៃច្បាប់នេះ ។

-ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជានិច្ចកាល ត្រូវប្រកាន់ខ្ជាប់នូវការអនុវត្តគោលការណ៍បង្ការ និងទប់ស្កាត់ចំពោះហានីភ័យដែលអាចបង្កឡើងដោយផ្ទាល់ ឬដោយប្រយោលពីការអនុវត្តគម្រោងអភិវឌ្ឍន៍ ។ ក្នុងករណីដែលសិក្សាឃើញថាស្ថានភាពបរិស្ថានអាចនឹងត្រូវប្រឈមជាមួយនឹងការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរ ឬត្រូវរងការខូចខាតមិនអាចជួសជុលបាន នោះភាពស្រពិចស្រពិល ឬភាពខ្វះចន្លោះខាងវិទ្យាសាស្ត្រមិនត្រូវយកមកបកស្រាយ ឬលើកយកមកសម្អាងធ្វើជាមូលដ្ឋាន ដើម្បីបដិសេធអត្ថិភាពនៃហានីភ័យចំពោះគុណភាពបរិស្ថាន និងធនធានជីវៈចម្រុះទាំងនោះឡើយ ។ វិមតិសង្ស័យក្នុងករណីនេះត្រូវបកស្រាយជាប្រយោជន៍ដល់ការហាមឃាត់ការអនុវត្តគម្រោង ។

-ត្រូវប្រកាន់យក និងអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍សមធម៌រវាងអ្នកជំនាន់នេះ និងអ្នកជំនាន់ក្រោយ ដោយធានាថាសេចក្តីត្រូវការដែលមាននាពេលបច្ចុប្បន្ន មិនត្រូវប៉ះពាល់ការបំពេញសេចក្តីត្រូវការរបស់អ្នកជំនាន់ក្រោយឡើយ ។

-បុគ្គលគ្រប់រូប ជារូបវន្តបុគ្គលក្តី នីតិបុគ្គលនៃនីតិឯកជនក្តី នីតិបុគ្គលនៃនីតិសាធារណៈក្តី ដែលបាន ឬនឹងបង្កឲ្យមានការបំពុលបរិស្ថាន ទោះក្រោមរូបភាពជាការបំពុលដោយសំឡេង រំញ័រ ក្លិនផ្សេង ការបង្ហូរសំណល់រាវ ឬការបញ្ចេញសំណល់គ្រប់ប្រភេទ ឬការបង្កការខូចខាតដល់បរិស្ថាន ឬដល់សុខភាព ឬសេដ្ឋកិច្ច ឬសង្គម ឬវប្បធម៌ណាមួយ ត្រូវរ៉ាប់រងបង់ថ្លៃចំណាយដើម្បីជួសជុលការខូចខាត ទប់ស្កាត់ បញ្ចៀស ក៏ដូចជាកាត់បន្ថយការខូចខាតទាំងនោះ ។

# ជំពូកទី ៣

# អង្គភាពទទួលខុសត្រូវ

## មាត្រា ៨._

ក្រសួងបរិស្ថាន ជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាល ដែលមានសមត្ថកិច្ចផ្តាច់មុខសម្រាប់គ្រប់គ្រងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ក្រសួងបរិស្ថានមានភារកិច្ចដូចខាងក្រោមៈ

-បង្កើតគណៈកម្មការជំនាញត្រួតពិនិត្យ តាមការចាំបាច់

-ចេញលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

-អនុម័តគោលការណ៍ណែនាំស្តីពីលក្ខណៈវិនិច្ឆ័យនៃការធ្វើចំណាត់ថ្នាក់គម្រោង

-កំណត់លក្ខណៈវិនិច្ឆ័យនៃវិសាលភាពគម្រោង និងល័ក្ខខ័ណ្ឌការងារ

-អនុម័តគោលការណ៍ណែនាំនានា ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ និង/ឬ ផែនការគ្រប់គ្រងបរិស្ថាន

-អនុវត្តគោលការណ៍នានាដែលបានឯកភាព និងអនុវត្តដោយក្រសួងបរិស្ថានស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ប្លែនការគ្រប់គ្រងបរិស្ថាន

-អនុម័តគោលការណ៍ណែនាំស្តីពីការចូលរួមជាសាធារណៈ ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

-កំណត់ល័ក្ខខ័ណ្ឌ លក្ខណៈសម្បត្តិ បែបបទនិងនីតិវិធីសម្រាប់ការចុះបញ្ជីទីប្រឹក្សានៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

-បង្កើត និងអភិវឌ្ឍ ក្របខ័ណ្ឌច្បាប់នានា សម្រាប់អនុវត្តចំពោះការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ជាអាទ៍ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងវិធីសាស្ត្រវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ។

## មាត្រា ៩._

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺជាសេនាធិការផ្ទាល់ របស់ក្រសួងបរិស្ថាន សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការវាយតម្លៃបរិស្ថានយុទ្ធសាស្ត្រ ។

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានរចនាសម្ព័ន្ធចាត់តាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ការរៀបចំ និងប្រព្រឹត្តទៅនៃអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១០._**

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសមត្ថកិច្ចដូចខាងក្រោម៖

-ត្រួតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងចេញលិខិតអនុញ្ញាត និងសេចក្តីសម្រេចនានាពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អនុលោមតាមច្បាប់ និងនីតិវិធីជាធរមានបន្ទាប់ពីមានសេចក្តីសម្រេចពីរដ្ឋមន្ត្រីក្រសួងបរិស្ថាន ។

-តាមដាន ត្រួតពិនិត្យ ធ្វើអធិការកិច្ច អង្កេត ស្រាវជ្រាវ ណែនាំ និងចាត់វិធានការដោយខ្លួនឯង ឬដោយសហការជាមួយភាគីពាក់ព័ន្ធ ចំពោះការអនុវត្តគម្រោង និងសកម្មភាពគ្រប់ប្រភេទ ។

**មាត្រា ១១._**

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានភារកិច្ចដូចខាងក្រោម៖

-ទទួលបន្ទុកអនុវត្តច្បាប់នេះ ក្រោមការត្រួតពិនិត្យពីក្រសួងបរិស្ថាន

-ទទួលបន្ទុកធ្វើចំណាត់ថ្នាក់គម្រោងដែលស្នើសុំ កំណត់វិសាលភាពនៃគម្រោង និងល័ក្ខខ័ណ្ឌការងារ ពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងឯកសារទាំងអស់ដែលពាក់ព័ន្ធ និងធានាឲ្យមានការចូលរួមជាសាធារណៈអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

-ចុះអង្កេត និងតាមដានរាល់សកម្មភាពគម្រោងទៅតាមផែនការត្រួតពិនិត្យតាមដាន និងគ្រប់គ្រងបរិស្ថាន ក្រោយពីម្ចាស់គម្រោងទទួលបានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីធានាការគោរពច្បាប់ ។

**មាត្រា ១២._**

មន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន មានសិទ្ធិ អំណាចដូចខាងក្រោម៖

-ធ្វើអធិការកិច្ចតាមដាន និងត្រួតពិនិត្យការគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន គោលការណ៍ណែនាំនានា កិច្ចសន្យាការពារបរិស្ថាន ស្តង់ដារ ផែនការគ្រប់គ្រងបរិស្ថាន និងល័ក្ខខ័ណ្ឌតម្រូវផ្នែកបរិស្ថានដែលពាក់ព័ន្ធផ្សេងៗទៀត ។ ក្នុងករណីចាំបាច់ មន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អាចបង្គាប់ឱ្យម្ចាស់គម្រោងផ្អាកសកម្មភាពមួយផ្នែក ឬទាំងស្រុងជាបណ្តោះអាសន្ន ឬបិទទីតាំងជាបណ្តោះអាសន្ន ។

-ពិនិត្យកំណត់ត្រា ឯកសារ ទិន្នន័យអេឡិចត្រូនិក ស្តីពីការគ្រប់គ្រងបរិស្ថាន និងកំណត់ត្រា ដទៃទៀត ស្តីពីគម្រោងអភិវឌ្ឍន៍ និងការប្រតិបត្តិគម្រោង ។

-ស្តាប់ និងធ្វើកំណត់ហេតុស្តាប់ចម្លើយរបស់កម្មករ និយោជិត តំណាងម្ចាស់គម្រោង ក៏ដូចជា បុគ្គលពាក់ព័ន្ធនានា ។

-បង្គាប់ឲ្យកម្មករ និយោជិត អភិបាល អ្នកតំណាងស្របច្បាប់ និងភ្នាក់ងារនៃគម្រោងអភិវឌ្ឍន៍ ផ្តល់នូវរាល់ព័ត៌មាន ឯកសារជាលាយលក្ខណ៍អក្សរ ផែនការក៏ដូចជាកំណត់ត្រាគ្រប់ប្រភេទដែលពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង ។

-មានសិទ្ធិចុះឆែកឆេរទីតាំងគម្រោង និងចាប់យកវត្ថុតាង ក្នុងករណីដែលសង្ស័យថាមានអំពើល្មើសនឹងច្បាប់ ឬបទប្បញ្ញត្តិនានាស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន ។

-ជួបប្រជុំជាមួយប្រធានក្រុមប្រឹក្សាភិបាល តំណាងស្របច្បាប់ និងកម្មករ និយោជិតនៃគម្រោងយ៉ាងតិច ១ (មួយ) ឆ្នាំ ម្តង ដើម្បីធ្វើការវាយតម្លៃការអនុវត្តច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត ។

-ធ្វើកំណត់ហេតុផែកឆេរ និងចាប់យកវត្ថុតាងនានា ដើម្បីកសាងសំណុំរឿងនៃការប្រព្រឹត្តល្មើសនឹងច្បាប់នេះ ដើម្បីចាត់ការតាមនីតិវិធីជាធរមាន ។

**មាត្រា ១៣._**

មន្ទីរបរិស្ថានរាជធានី ខេត្ត ចូលរួមអនុវត្តច្បាប់នេះ អនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តិ ជាធរមាន ព្រមទាំងការចាត់តាំងរបស់ក្រសួងបរិស្ថាន ។

# ជំពូកទី ៤

# កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ផ្នែកទី១

## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងស្នើសុំ

**មាត្រា ១៤._**

ក្រសួងបរិស្ថានត្រូវកំណត់ចំណាត់ថ្នាក់លើគម្រោងអភិវឌ្ឍន៍ ដើម្បីតម្រូវឱ្យម្ចាស់គម្រោងរៀបចំនូវឯកសារ ដូចខាងក្រោម ៖

១.របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ភ្ជាប់ជាមួយកិច្ចសន្យាការពារ បរិស្ថាន

២.របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន

៣.កិច្ចសន្យាការពារបរិស្ថាន ។

ប្រភេទគម្រោងដែលតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យ ។

គម្រោងដែលតម្រូវឱ្យរៀបចំ កិច្ចសន្យាការពារបរិស្ថាន ត្រូវភ្ជាប់ជាមួយគោលការណ៍បច្ចេកទេសជាអាទិ៍ ផែនការគាំពារបរិស្ថាន ដោយត្រូវអនុលោមតាមល័ក្ខខ័ណ្ឌតម្រូវរបស់ក្រសួងបរិស្ថាន ។

ក្រសួងបរិស្ថាន អាចកំណត់ចំណាត់ថ្នាក់គម្រោងបន្ថែមទៀត ដោយផ្អែកលើទំហំនៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១៥**

ក្នុងករណីដែលមានការផ្ទេរ ឬផ្លាស់ប្តូរម្ចាស់គម្រោង ដោយហេតុណាមួយ នោះលិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និង/ឬ ពេញលេញ ព្រមទាំងកិច្ចសន្យា និងល័ក្ខខ័ណ្ឌទាំងអស់ដែលចែងក្នុងវាក្យខណ្ឌនេះ ត្រូវផ្ទេរទៅម្ចាស់ថ្មីដោយស្វ័យប្រវត្តិ ។ កិច្ចសន្យាផ្ទេរ ឬ

ការផ្លាស់ប្តូរម្ចាស់គម្រោងមានសុពលភាពអនុវត្ត លុះត្រាណាតែការផ្ទេរ ឬការផ្លាស់ប្តូរនោះ ធ្វើឡើងបន្ទាប់ពីក្រសួងបរិស្ថាន ទទួលបានការជូនដំណឹងអំពីការផ្លាស់ប្តូរនោះ ។

**មាត្រា ១៦._**

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ត្រូវធ្វើឡើងសម្រាប់៖

១.គម្រោងនានាដែលមានរៀបរាប់ក្នុងអនុក្រឹត្យ ឬ

២.គម្រោងនានា ដែលបានរៀបចំជាកិច្ចសន្យាការពារបរិស្ថាន ហើយក្រសួងបរិស្ថានតម្រូវឲ្យធ្វើរបាការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ។

នៅពេលដែលគម្រោងស្នើឡើង ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង នោះម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា ដើម្បីរៀបចំសេចក្តីព្រាងល័ក្ខខ័ណ្ឌការងារ ដោយអនុលោមតាមបទប្បញ្ញត្តិ និងគោលការណ៍ណែនាំនានារបស់ក្រសួងបរិស្ថាន រួចដាក់សុំការអនុម័តជាស្ថាពរពីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ផ្អែកលើល័ក្ខខ័ណ្ឌការងារដែលទទួលបានការឯកភាព ។

**មាត្រា ១៧._**

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវធ្វើឡើងសម្រាប់៖

១-គម្រោងដែលកំណត់ដោយអនុក្រឹត្យ ឬ

២-គម្រោងដែលទទួលបានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ហើយលទ្ធផលនៃការសិក្សានេះពិនិត្យឃើញថាមានការប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គម ហើយក្រសួងបរិស្ថានតម្រូវឱ្យមានការសិក្សារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

នៅពេលដែលគម្រោងស្នើសុំ តម្រូវឲ្យធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា ដើម្បីរៀបចំសេចក្តីព្រាងល័ក្ខខ័ណ្ឌការងារ ដោយអនុលោមតាមបទប្បញ្ញត្តិ និងគោលការណ៍ណែនាំនានារបស់ក្រសួងបរិស្ថាន រួចដាក់សុំការអនុម័តជាស្ថាពរពីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវ រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ផ្អែកលើល័ក្ខខ័ណ្ឌការងារដែលទទួលបានការឯកភាព ។

**មាត្រា ១៨._**

កិច្ចសន្យាការពារបរិស្ថាន ត្រូវធ្វើឡើងសម្រាប់គម្រោងនានាដែលមានរៀបរាប់ក្នុងអនុក្រឹត្យ ឬគម្រោងដែលមានទំហំហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គមតិចតួច ។

នៅពេលដែលគម្រោងស្នើឡើងត្រូវធ្វើត្រឹមកិច្ចសន្យាការពារបរិស្ថាន នោះម្ចាស់គម្រោង ត្រូវចុះកិច្ចសន្យាការពារបរិស្ថាន ដោយត្រូវភ្ជាប់ជាមួយគោលការណ៍បច្ចេកទេស ជាអាទិ៍ ផែនការគាំពារបរិស្ថាន និងឯកសារពាក់ព័ន្ធ រួចដាក់សុំការអនុម័តជាស្ថាពរពីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

គំរូកិច្ចសន្យាការពារបរិស្ថាន និងផែនការគាំពារបរិស្ថាន ត្រូវកំណត់ដោយក្រសួងបរិស្ថាន ។

**មាត្រា ១៩._**

រាល់គម្រោងអភិវឌ្ឍន៍នានា ដែលតម្រូវឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ចាំបាច់ត្រូវមានមតិបច្ចេកទេសរបស់គណៈកម្មការជំនាញត្រួតពិនិត្យ ។

គណៈកម្មការជំនាញត្រួតពិនិត្យនេះរួមមានសមាសភាពនៃមន្ត្រីមកពីក្រសួងបរិស្ថាន ក្រសួងស្ថាប័នពាក់ព័ន្ធ និងអ្នកជំនាញឯករាជ្យ ដែលមានគុណសម្បត្តិ និងបទពិសោធន៍សមស្របក្នុងការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

សមាជិកគណៈកម្មការជំនាញត្រួតពិនិត្យនេះ អាចមានការប្រែប្រួលពីគម្រោងមួយទៅគម្រោងមួយ តាមការជ្រើសរើសរបស់ក្រសួងបរិស្ថាន អាស្រ័យទៅតាមទិដ្ឋភាពបច្ចេកទេសនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃការបង្កើតគណៈកម្មការជំនាញត្រួតពិនិត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

សមាជិកនៃគណៈកម្មការជំនាញត្រួតពិនិត្យ ត្រូវបានទូទាត់ប្រាក់កម្រៃសម្រាប់ការបម្រើការងាររបស់ខ្លួន ដោយផ្អែកលើការព្រមព្រៀង រវាងក្រសួងបរិស្ថាន និងសមាជិក ដោយអនុលោមតាមគោលការណ៍ណែនាំអំពីថ្លៃ និងបន្ទុកសេវាបរិស្ថាន ។

**មាត្រា ២០._**

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ អាចយកជាបានការលុះត្រាតែះ

១-របាយការណ៍នោះត្រូវបានរៀបចំឡើង ដោយនីតិបុគ្គលដែលក្រសួងបរិស្ថានបានផ្តល់ជូននូវនីតិសម្បទាជាក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

២-របាយការណ៍នោះត្រូវ គាក់តែងឡើងស្របតាមនីតិវិធី ល័ក្ខខ័ណ្ឌ និងគោលការណ៍ណែនាំ ដែលកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ២១._**

ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលជារូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ។

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវមានសញ្ជាតិខ្មែរ និងមានប្រធានក្រុមការងារជាទីប្រឹក្សាដែលទទួលបាននីតិសម្បទាពក្រសួងបរិស្ថាន ។

បុគ្គលជាទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានគ្រប់រូប ត្រូវចុះបញ្ជីនៅក្រសួងបរិស្ថានជាមុនសិនមុននឹងប្រកបវិជ្ជាជីវៈរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជាមួយក្រុមហ៊ុនទីប្រឹក្សា ។

វិញ្ញាបនបត្រនៃការចុះបញ្ជី ផ្តល់នីតិសម្បទាជាទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវមានរយៈពេលសុពលភាពអតិបរិមា ៥ (ប្រាំ) ឆ្នាំ ហើយអាចបន្តសាជាថ្មីបាន ។

គុណវុឌ្ឍិ បែបបទ ល័ក្ខខ័ណ្ឌ និងនីតិវិធីសម្រាប់ចុះបញ្ជីដើម្បីទទួលបាននីតិសម្បទាជាទីប្រឹក្សារូបវន្តបុគ្គល ឬនីតិបុគ្គលសម្រាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក៏ដូចជាការបន្តសុពលភាពនៃការចុះបញ្ជីសារជាថ្មី ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ២២._**

ក្រសួងបរិស្ថានមានរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីពិនិត្យ ផ្តល់យោបល់ឯកភាព បដិសេធ ឬតម្រូវឱ្យកែសម្រួល ឬកែតម្រូវ លើកិច្ចសន្យាការពារបរិស្ថាន និងផែនការគាំពារបរិស្ថាន។ រយៈពេលនេះគិតចាប់ពីកាលបរិច្ឆេទដែលខ្លួនទទួលបានពាក្យសុំពិនិត្យលើកិច្ចសន្យាការពារបរិស្ថាន ផែនការគាំពារបរិស្ថាន និងឯកសារពាក់ព័ន្ធ ។

**មាត្រា ២៣_**

ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលខ្លួនទទួលបានរបាយការណ៍នោះ ។ រយៈពេល ៦០ (ហុកសិប) ថ្ងៃនេះ ត្រូវអស់សុពលភាព នៅពេលដែលក្រសួងបរិស្ថានបានផ្តល់យោបល់របស់ខ្លួន ទោះបីជាជាយោបល់នោះជាយោបល់បដិសេធ យោបល់ឯកភាព ឬជាយោបល់បង្គាប់ឱ្យមានការកែប្រែ ឬកែលម្អ របាយការណ៍ដែលខ្លួនពិនិត្យក៏ដោយ ។

រយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ សម្រាប់ពិនិត្យ និងផ្តល់យោបល់ខាងលើ ជានិច្ចកាល ត្រូវចាប់ផ្តើមរាប់សារជាថ្មី នៅពេលដែលក្រសួងទទួលបានពាក្យស្នើសុំឱ្យពិនិត្យ ព្រមទាំងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលម្ចាស់គម្រោងបានធ្វើការកែតម្រូវរួចជាស្ថាពរ ស្របតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំ ដែលក្រសួងបរិស្ថានបានផ្តល់ជូនជាគ្រាមុនៗ ។

ម្ចាស់គម្រោង ត្រូវទទួលខុសត្រូវ ចំពោះព្យសនកម្មនានា ដែលបង្កឡើងដោយកំហុសរបស់ខ្លួនដែលបណ្តាលមកពីការយឺតយ៉ាវ ឬការខកខានមិនបានធ្វើការកែសម្រួលឱ្យត្រូវតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំខាងលើ ។

**មាត្រា ២៤_**

ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់ លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលខ្លួនទទួលបានរបាយការណ៍នោះ។ រយៈពេល៩០(កៅសិប)ថ្ងៃនេះ ត្រូវអស់សុពលភាព នៅពេលដែលក្រសួងបរិស្ថានបានផ្តល់យោបល់របស់ខ្លួន ទោះបីជាជាយោបល់នោះជាយោបល់បដិសេធ យោបល់ឯកភាព ឬជាយោបល់បង្គាប់ឱ្យមានការកែប្រែ ឬកែលម្អ របាយការណ៍ដែលខ្លួនពិនិត្យក៏ដោយ ។

រយៈពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ សម្រាប់ពិនិត្យ និងផ្តល់យោបល់ខាងលើ ជានិច្ចកាល ត្រូវចាប់ផ្តើមរាប់សារជាថ្មី នៅពេលដែលក្រសួងទទួលបានពាក្យស្នើសុំឱ្យពិនិត្យ ព្រមទាំងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលម្ចាស់គម្រោងបានធ្វើការកែតម្រូវរួចជាស្ថាពរ ស្របតាមសេចក្តីបង្គាប់ ឬណែនាំដែលក្រសួងបរិស្ថានបានផ្តល់ជូនជាគ្រាមុនៗ ។

ម្ចាស់គម្រោង ត្រូវទទួលខុសត្រូវ ចំពោះព្យសនកម្មនានាដែលបង្កឡើងដោយកំហុសរបស់ខ្លួនដែលបណ្តាលមកពីការយឺតយ៉ាវ ឬការខកខានមិនបានធ្វើការកែសម្រួលឱ្យត្រូវតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំខាងលើ ។

**មាត្រា ២៥._**

ក្នុងអំឡុងពេលនៃការពិនិត្យ និងផ្តល់យោបល់ដែលកំណត់ក្នុងមាត្រា ២៣ និង មាត្រា ២៤ នៃច្បាប់នេះ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់របស់ខ្លួន ចំពោះរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ បន្ទាប់ពី៖

-ស្តាប់និងពិចារណាលើបទបង្ហាញ និងការការពារជាផ្លូវការរបស់ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា

-ពិចារណាលើមតិយោបល់ របស់អ្នកដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល មតិសាធារណជនពាក់ព័ន្ធ និងសង្គមស៊ីវិល

-ពិចារណាមតិយោបល់របស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ និង

-ពិចារណាមតិរបស់គណៈកម្មការជំនាញត្រួតពិនិត្យដែលបានស្នើឡើង ។

ក្រសួងបរិស្ថានទទួលខុសត្រូវ ក្នុងការរៀបចំឱ្យមានដំណើរការចូលរួមជាសាធារណៈ ប្រកបដោយសមធម៌ ដោយអញ្ជើញតំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី សង្គមស៊ីវិល និងអ្នកដែលទទួលរងការប៉ះពាល់ ឲ្យចូលរួមផ្តល់មតិយោបល់ចំពោះគម្រោងដែលបានស្នើឡើងនោះ ។

**មាត្រា ២៦._**

ការផ្តល់យោបល់ឯកភាព ឬបដិសេធ ឬបង្គាប់ឱ្យមានការកែប្រែ ឬកែតម្រូវផ្សេងៗទៅលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវធ្វើឡើងដោយពិចារណាលើគុណសម្បត្តិ និងគុណវិបត្តិខាងផ្នែកបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ តាមរយៈការពិនិត្យជាអាទិ៍៖ វិសាលភាពនៃគម្រោង ទីតាំងភូមិសាស្ត្រ សក្តានុពលនៃហេតុប៉ះពាល់ លក្ខណៈពិសេសដទៃទៀតរបស់គម្រោងនីមួយៗ និងប្រសិទ្ធភាពនៃការអនុវត្តវិធានការគ្រប់គ្រង និង/ឬការពារគុណភាពបរិស្ថាន និងកាត់បន្ថយហេតុប៉ះពាល់ចំពោះសង្គម អនុលោមតាមកម្រិតវិវឌ្ឍន៍ នៃបច្ចេកវិជ្ជា និងវិទ្យាសាស្ត្រ ។

ក្នុងករណីក្រសួងបរិស្ថាន ផ្តល់យោបល់ឯកភាព លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ក្រសួងបរិស្ថានត្រូវចេញលិខិតនិងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងនោះ ដោយភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន ។ ក្នុងករណី ក្រសួងបរិស្ថានបដិសេធលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ក្រសួងបរិស្ថានត្រូវបញ្ជាក់ពីហេតុផលនៃសេចក្តីសម្រេចរបស់ខ្លួន ។

ក្នុងករណីក្រសួងបរិស្ថាន ផ្តល់យោបល់បង្គាប់ឱ្យធ្វើការកែប្រែ ឬកែតម្រូវលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ នោះក្រសួងបរិស្ថានត្រូវភ្ជាប់ហេតុផល និងចង្អុលបង្ហាញដោយច្បាស់ៗ នូវចំណុចត្រូវកែប្រែ ឬកែតម្រូវ ។

**មាត្រា ២៧._**

មុនសម្រេចផ្តល់នូវលិខិតនិង វិញ្ញាបនបត្រឯកភាព លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងអភិវឌ្ឍន៍ ដែលមានទីតាំងស្ថិតនៅតំបន់ ដែលមានជនជាតិដើមភាគតិចរស់នៅ ក្រសួងបរិស្ថាន សមាជិកនៃគណៈកម្មការជំនាញត្រួតពិនិត្យ ឬអ្នកពាក់ព័ន្ធក្នុងការចូលរួមក្នុងការសម្រេច ត្រូវធ្វើការយកចិត្តទុកដាក់ និងពិចារណាខ្ពស់ចំពោះគម្រោងនោះដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមាន ជាអាទិ៍ វប្បធម៌ ទំនៀមទំលាប់ ប្រពៃណី ការប្រកបរបរចិញ្ចឹមជីវិត ទ្រព្យសម្បត្តិ ដល់សហគមន៍ជនជាតិដើមភាគតិច ។

**មាត្រា ២៨._**

ក្រសួងបរិស្ថាន ត្រូវផ្ញើសេចក្តីសម្រេចបដិសេធ ឬសេចក្តីបង្គាប់ឱ្យមានការកែប្រែ ឬកែតម្រូវជាលាយលក្ខណ៍អក្សររបស់ខ្លួន រួមទាំងហេតុផល ឬលក្ខខ័ណ្ឌ និង/ឬ ចំណុចនានាដែលត្រូវកែប្រែ ឬកែតម្រូវ ជូនទៅម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាសម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ក្រសួងបរិស្ថានត្រូវផ្ញើលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន រួមទាំងកិច្ចសន្យាការពារបរិស្ថាន ជូនដល់ម្ចាស់គម្រោង និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធជាអាទិ៍៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួង ឬស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ មន្ទីរបរិស្ថានរាជធានី ខេត្ត និងក្រុមប្រឹក្សាឃុំ-សង្កាត់ពាក់ព័ន្ធ ។

ក្រសួងបរិស្ថាន ត្រូវផ្សព្វផ្សាយសេចក្តីសម្រេចឯកភាពរបស់ខ្លួន រួមទាំងផែនការគ្រប់គ្រងបរិស្ថាន និងលក្ខខ័ណ្ឌពាក់ព័ន្ធខាងលើ ជូនដល់សាធារណជន តាមរយៈការដាក់បង្ហោះនៅលើគេហទំព័ររបស់ខ្លួន និង/ឬ តាមរយៈការបោះពុម្ពផ្សាយតាមសារព័ត៌មាន អនុលោមតាមកាលៈទេសៈ និងភាពចាំបាច់ ។

**មាត្រា ២៩._**

ម្ចាស់គម្រោងមិនត្រូវចាប់ផ្តើមសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោង មុនពេលទទួលបានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ ក្នុងករណីដែលគម្រោងអភិវឌ្ឍន៍គ្មានលិខិត និងវិញ្ញាបនបត្រ ឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រសួងបរិស្ថានមានសិទ្ធិសម្រេចផ្អាកសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោង ទាំងស្រុង ។

រាល់កិច្ចព្រមព្រៀងសម្បទាន ដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត ត្រូវមានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាផ្លូវការដោយភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន ។

**មាត្រា ៣០._**

លិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសុពលភាព សម្រាប់រយៈពេលវដ្តនៃគម្រោង ។ ក្នុងករណីក្រសួងបរិស្ថានពិនិត្យឃើញថា មានការផ្លាស់ប្តូរផែនការមេ ឬ/និង របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ លែងមានលក្ខណៈសមស្រប ឬមិនមានប្រសិទ្ធិភាពក្នុងការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់ ក្រសួងបរិស្ថានមានសិទ្ធិតម្រូវឱ្យម្ចាស់គម្រោង រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានឡើងវិញ ឬ/និង ធ្វើបច្ចុប្បន្នភាព របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីទទួលបានជាថ្មីនូវលិខិត និងវិញ្ញាបនបត្រឯកភាពលើ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន តាមលក្ខខណ្ឌកំណត់ដោយក្រសួងបរិស្ថាន ។

## ផ្នែកទី២
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងដែលមានស្រាប់ និងកំពុងដំណើរការ

**មាត្រា ៣១._**

ក្រសួងបរិស្ថានត្រូវពិគ្រោះយោបល់ជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំគោលការណ៍ណែនាំផ្អែកលើការចាត់ថ្នាក់គម្រោងសម្រាប់ប្រភេទគម្រោង ដែលមិនបានអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីតម្រូវឲ្យម្ចាស់គម្រោងទាំងនោះ រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ចំពោះគម្រោងដែលមានស្រាប់ និងកំពុងដំណើរការ។

គោលការណ៍ណែនាំត្រូវបោះពុម្ពផ្សព្វផ្សាយក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីពេលក្រសួងបរិស្ថានសម្រេចលើគោលការណ៍ណែនាំទាំងនេះ ។

ម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឲ្យបានចប់ ហើយត្រូវដាក់ឯកសារទាំងនេះ ទៅក្រសួងបរិស្ថានដើម្បីពិនិត្យ ផ្តល់យោបល់ ក្នុងរយៈពេលកំណត់ដោយក្រសួងបរិស្ថាន ។

ក្រសួងបរិស្ថានត្រូវពិនិត្យ ផ្តល់យោបល់ និងសម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដោយយោងទៅតាមខ្លឹមសារនៃជំពូក ៤ នៃច្បាប់នេះ ។

## ផ្នែកទី ៣
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះការប្រែប្រួលអាកាសធាតុ

**មាត្រា ៣២._**

រាល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវវិភាគ និងវាយតម្លៃ ពីសក្តានុពលនៃផលប៉ះពាល់ និងភាពងាយរងគ្រោះនៃគម្រោង ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងសកម្មភាពអភិវឌ្ឍន៍ដែលអាចរងនូវអតុល្យភាពដោយសារល័ក្ខខ័ណ្ឌបរិស្ថានដែលរងការប៉ះពាល់ ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិច ដែលជាទិសដៅចម្បងនៃការអភិវឌ្ឍន៍បៃតង។

ក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោងត្រូវដាក់បញ្ចូលនូវការវាយតម្លៃហានិភ័យ ភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ ភាពបន្សុាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីស្នើនូវវិធានការកាត់បន្ថយផលប៉ះពាល់នូវហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងដាក់បញ្ចូលនូវរាល់ផែនការឆ្លើយតបបន្ទាន់ និងជម្រើសបច្ចេកវិទ្យា ដើម្បីទប់ទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ។

**មាត្រា ៣៣_**

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវដាក់បញ្ចូលនូវការគណនាបរិមាណនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់គម្រោងអភិវឌ្ឍន៍ រួមបញ្ចូល ការវិភាគលើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នាពេលអនាគត ។

ម្ចាស់គម្រោងត្រូវសិក្សាអំពីជម្រើសថាមពលនានា ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាប និងសិក្សាអំពីតម្រូវការក្នុងការកាត់បន្ថយការប្រែប្រួលចំពោះការផ្គត់ផ្គង់ទឹក ដែលបណ្តាលមកពីកត្តាអាកាសធាតុ។

## ផ្នែកទី ៤
## ការវាយតម្លៃហេតុប៉ះពាល់ជាបណ្តុំ

**មាត្រា ៣៤._**

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវវិភាគនិងវាយតម្លៃពីបណ្តុំនៃផលប៉ះពាល់ដែលបង្កឡើងដោយគម្រោងដែលមានស្រាប់ និងគម្រោងក្នុងពេលអនាគត នៅជុំវិញនៃទីតាំងគម្រោងទាំងនោះ ដែលអាចបង្កើតឲ្យមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ ដល់បរិស្ថាន ឬសង្គម ។

នៅក្នុងរបាយការណ៍វាយតម្លៃបណ្តុំនៃផលប៉ះពាល់ ម្ចាស់គម្រោងត្រូវវាយតម្លៃសមត្ថភាពនៃធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម ដើម្បីគិតគូរអំពីផលប៉ះពាល់បន្ថែមផ្អែកលើកត្តាពេលវេលា ស្ថានភាពភូមិសាស្ត្រ និងសកម្មភាពរបស់គម្រោងនានាដែលនៅជុំវិញទីតាំងគម្រោង ។

ម្ចាស់គម្រោងត្រូវពិចារណាអំពី ជម្រើសនៃវិធានការកាត់បន្ថយបណ្តុំនៃផលប៉ះពាល់ផ្សេងៗ ដើម្បីកាត់បន្ថយ ឬបញ្ចៀស បណ្តុំនៃផលប៉ះពាល់ដែលគួរឱ្យកត់សម្គាល់ទាំងនោះ ។

## ផ្នែកទី ៥
## ការវាយតម្លៃហេតុប៉ះពាល់សុខភាព

**មាត្រា ៣៥._**

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ត្រូវរាប់បញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់សុខភាព ដែលមានជាអាទិ៍៖

-ទិន្នន័យមូលដ្ឋាន ស្តីពីសុខភាពនៅក្នុងតំបន់គម្រោង និងរបស់ប្រជាជនដែលរងផលប៉ះពាល់

-ការពិពណ៌នា អំពីផលប៉ះពាល់នៃគម្រោងដែលអាចមាន ដោយសារការសាងសង់ លំហូរប្រជាជន និងការផ្លាស់ប្តូរចំពោះបរិស្ថាន

-វិធានការកាត់បន្ថយផលប៉ះពាល់ ដើម្បីកាត់បន្ថយ ឬលុបបំបាត់ផលប៉ះពាល់អវិជ្ជមាននៃគម្រោង និងវិធានការដែលត្រូវដាក់ឲ្យអនុវត្តដោយម្ចាស់គម្រោង ដើម្បីកែលម្អសុខភាពរបស់សហគមន៍មូលដ្ឋាន

-បញ្ហានានាទាក់ទងនឹងការអង្កេតតាមដានសុខភាព និងការគ្រប់គ្រងផលប៉ះពាល់ដែលនៅសល់ក្នុងរយៈពេលខ្លី និងវែង សម្រាប់គម្រោង ។

**មាត្រា ៣៦._**

ក្នុងការវាយតម្លៃហេតុប៉ះពាល់សុខភាព ម្ចាស់គម្រោងត្រូវ៖

-លើកផែនការគ្រប់គ្រងសុវត្ថិភាព និងសុខភាព ជាផ្នែកមួយនៃការវាយតម្លៃហេតុប៉ះពាល់សុខភាព សម្រាប់បរិស្ថានការងារ ដោយវិភាគពីហានិភ័យដែលពាក់ព័ន្ធ និងប្រភេទនៃកត្តាគ្រោះថ្នាក់ក្នុងទីតាំងគម្រោង ជាអាទិ៍ កត្តាគ្រោះថ្នាក់ផ្នែករូបសាស្ត្រ-គីមីសាស្ត្រ ជីវសាស្ត្រ និងវិទ្យុសកម្ម ។

-កំណត់ និងវាយតម្លៃពីគ្រោះហានិភ័យ និងសក្តានុពលនៃផលប៉ះពាល់ទៅលើ សុវត្ថិភាព និងសុខភាព របស់សហគមន៍ក្នុងដំណាក់កាលរចនាគម្រោង សាងសង់គម្រោង ប្រតិបត្តិគម្រោង និងបញ្ចប់គម្រោង ព្រមទាំងលើកវិធានការការពារ និងផែនការគ្រប់គ្រងផលប៉ះពាល់នៅក្នុងដំណាក់កាលទាំងនេះ ។

# ជំពូកទី ៥

# ការចូលរួមជាសាធារណៈ

**មាត្រា ៣៧._**

គោលបំណងចម្បងនៃការចូលរួមជាសាធារណៈ គឺដើម្បីធានាថា អ្នកដែលទទួលរងផលប៉ះពាល់ និងភាគីពាក់ព័ន្ធ ៖

-បានទទួលដំណឹងគ្រប់ជ្រុងជ្រោយអំពីគម្រោង

-មានឱកាសចូលរួមក្នុងកិច្ចពិភាក្សា និងកិច្ចដំណើរការនៃការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងគម្រោង

-មានឱកាសចូលរួមក្នុងការអង្កេតតាមដានគម្រោង

ម្ចាស់គម្រោងដែលត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវដាក់បញ្ចូលការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈ ពីរដ្ឋបាលមូលដ្ឋាន សង្គមស៊ីវិល តំណាងសហគមន៍ ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត ទៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅដំណាក់កាលរៀបចំផែនការគម្រោង ដើម្បី៖

-កំណត់ផ្នែកដែលមានសារៈសំខាន់ផ្នែកបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌

-ប្រមូលមតិយោបល់ពីភាគីពាក់ព័ន្ធ និងដាក់បញ្ចូលមតិយោបល់ទាំងនោះ ទៅក្នុងកិច្ចដំណើរការនៃការធ្វើសេចក្តីសម្រេច ។

-ពិនិត្យគម្រោងស្នើសុំ និងពន្យល់ពីផលប៉ះពាល់បរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌

-ពិចារណាជម្រើសដទៃទៀត និងវិធានការកាត់បន្ថយផលប៉ះពាល់នានា ។

នីតិវិធីនៃការចូលរួមជាសាធារណៈ នៅក្នុងដំណាក់កាលសិក្សាពិគ្រោះយោបល់ ការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការអង្កេតតាមដានគម្រោង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៣៨._**

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវ៖

-កត់ត្រាទុកនូវយោបល់របស់សាធារណជនដែលបានចូលរួម នៅក្នុងដំណាក់កាលរៀបចំផែនការ និងដំណាក់កាលអនុវត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

-ផ្តោតលើបញ្ហានានា ដែលលើកឡើងដោយស្ត្រី និងបណ្តាជនដែលអាចទទួលរងគ្រោះខ្លាំងបំផុត ពីផលប៉ះពាល់ដែលអាចកើតមានពីគម្រោងដែលបានស្នើឡើង ។

-ដាក់បញ្ចូលនូវសេចក្តីលំអិត អំពីផលប៉ះពាល់របស់គម្រោងដល់សាធារណជន និងការទទួលយក ឬបដិសេធសំណើរបស់សាធារណជន ។

-ផ្តល់ហេតុផលនៃការបដិសេធឲ្យបានច្បាស់លាស់ នៅក្នុងករណីដែលម្ចាស់គម្រោងបដិសេធសំណើរបស់សាធារណជន ។

**មាត្រា ៣៩._**

កិច្ចដំណើរការចូលរួមសាធារណៈត្រូវធានាថា មានការយល់ព្រមពីសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ចំពោះវិធានការកាត់បន្ថយផលប៉ះពាល់ដែលបានស្នើឡើង ដោយផ្អែកលើគោលការណ៍យល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីជ្រាបព័ត៌មានគ្រប់ជ្រុងជ្រោយ ។

ក្នុងវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាននេះ ម្ចាស់គម្រោងត្រូវ ៖

-កំណត់វិធានការនានា ក្នុងការលើកកម្ពស់ជីវភាព និងជួយដល់អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ។

-ធានាថា អ្នកដែលទទួលរងផលប៉ះពាល់ បានចូលរួមក្នុងការរៀបចំការផ្លាស់ទីលំនៅថ្មីដើម្បីកាត់បន្ថយផលប៉ះពាល់នៃការផ្លាស់ទីលំនៅថ្មីឲ្យបានកម្រិតអប្បបរមា ក្នុងការធានាថាសំណងលើការបាត់បង់ទ្រព្យសម្បត្តិ ត្រូវបានដោះស្រាយដោយយុត្តិធម៌សមស្របជាមុនសិន និងដែលទទួលយកបានតាមតម្លៃទីផ្សារ ហើយវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថានមានលក្ខណៈត្រឹមត្រូវ ។

ក្នុងករណីដែលសហគមន៍ដែលរងផលប៉ះពាល់ មិនយល់ស្របចំពោះវិធានការកាត់បន្ថយនានាដែលម្ចាស់គម្រោងបានស្នើខាងលើ គម្រោងអភិវឌ្ឍន៍នៅតែបន្តដដែល ប៉ុន្តែម្ចាស់គម្រោងត្រូវកំណត់រកវិធានការកាត់បន្ថយផលប៉ះពាល់ផ្សេងទៀត ឬដោះស្រាយរាល់ផលប៉ះពាល់នោះដល់សហគមន៍ ។

នីតិវិធីនៃការដោះស្រាយសំណងដល់សហគមន៍ដែលទទួលរងផលប៉ះពាល់ និងនីតិវិធីនៃការផ្លាស់ប្តូលំនៅថ្មី ត្រូវកំណត់ដោយអនុក្រឹត្យ ។

បែបបទ និងនីតិវិធីនៃការទូទាត់សំណងការខូចខាត ដល់សហគមន៍ទទួលរងផលប៉ះពាល់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤០._**

ក្រសួងបរិស្ថានត្រូវធានាថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងឯកសារពាក់ព័ន្ធ រួមមាន លិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយភាគីពាក់ព័ន្ធ និងសហគមន៍ ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង អាចទទួលបានព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់ ។

ម្ចាស់គម្រោងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ តាមរយៈគេហទំព័ររបស់ខ្លួន យ៉ាងហោចណាស់ នូវឯកសារថតចម្លងនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ផែនការគ្រប់គ្រងបរិស្ថាននៃគម្រោង ផែនទី និងផែនការនៃគម្រោង ព្រមទាំងបណ្ដាវិធានការកាត់បន្ថយផលប៉ះពាល់នៃគម្រោងដែលត្រូវបានស្នើឡើង ។

នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

# ជំពូកទី ៦
# ផែនការគ្រប់គ្រងបរិស្ថាន និងការអង្កេតតាមដានគម្រោង

**មាត្រា ៤១._**

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងមន្ទីរបរិស្ថានរាជធានី ខេត្ត ជាអាជ្ញាធរត្រួតពិនិត្យលើផែនការគ្រប់គ្រងបរិស្ថាន និងអង្កេតតាមដានសកម្មភាពអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ ។

**មាត្រា ៤២._**

ផែនការគ្រប់គ្រងបរិស្ថានត្រូវរៀបចំដោយម្ចាស់គម្រោង ។

ផែនការគ្រប់គ្រងបរិស្ថានត្រូវដាក់បញ្ចូលល័ក្ខខ័ណ្ឌតម្រូវ នៃការការពារ ការកាត់បន្ថយ ការអង្កេតតាមដាន និងការគ្រប់គ្រង ដែលបានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ។

ផែនការគ្រប់គ្រងបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ ដោយអនុលោមតាមការវិវឌ្ឍន៍ជាក់ស្ដែងនៃស្តង់ដារបរិស្ថាន ឬការអនុវត្តជាក់ស្ដែងដែលទទួលស្គាល់ជាទូទៅក្នុងវិស័យនីមួយៗ ឬការប្រែប្រួលស្ថានភាពផ្សេងៗនៃគម្រោង ។

**មាត្រា ៤៣._**

រាល់គម្រោងអភិវឌ្ឍន៍ និងអ្នកប្រតិបត្តិការគម្រោង ត្រូវបង្កើត និងរក្សាប្រព័ន្ធគ្រប់គ្រងបរិស្ថានផ្ទៃក្នុងដែលត្រូវធានាឲ្យមាននូវនីតិវិធី និងវិធីសាស្ត្រអង្កេតតាមដានដោយខ្លួនឯង ដូចមានចែងក្នុងផែនការគ្រប់គ្រងបរិស្ថានរបស់ខ្លួន ។

ក្នុងករណីផលប៉ះពាល់បរិស្ថាន មានទំហំធំជាងផលប៉ះពាល់ដែលត្រូវបានប៉ាន់ប្រមាណនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន ក្រសួងបរិស្ថានតម្រូវឲ្យចាត់វិធានការកែតម្រូវផលប៉ះពាល់ភ្លាមៗ ឬកែតម្រូវផែនការគ្រប់គ្រងបរិស្ថាន ។

ផែនការគ្រប់គ្រងបរិស្ថានដែលបានកែតម្រូវរួច និងកម្មវិធីអង្កេតតាមដាន ត្រូវទទួលបានការឯកភាពពីក្រសួងបរិស្ថាន ។ រយៈពេលកំណត់ ដើម្បីធ្វើការកែតម្រូវ ឬកែលម្អជាថ្មីឡើងវិញ ត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរដោយភាគីពាក់ព័ន្ធ ។

ម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថានរៀងរាល់០៣ខែម្តង ហើយបញ្ជូនមកអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីពិនិត្យ និងវាយតម្លៃ ។ អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសិទ្ធិចុះត្រួតពិនិត្យដល់កន្លែង និងផ្ទៀងផ្ទាត់លទ្ធផល នៃការអង្កេតតាមដានរបស់ម្ចាស់គម្រោង ។

**មាត្រា ៤៤._**

អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ត្រូវមានសិទ្ធិរាយការណ៍ពីបញ្ហា និងក្តីកង្វល់បរិស្ថាន និងសង្គម ជូនដល់ម្ចាស់គម្រោង និងដាក់បណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ហើយបញ្ហាទាំងនោះត្រូវដោះស្រាយដោយអនុគណៈកម្មការថ្នាក់ក្រោមជាតិ និងអាចបន្តមកគណៈកម្មការអន្តរក្រសួងដែលបង្កើតឡើងជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងបរិស្ថាន ។

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវឆ្លើយតបចំពោះបណ្តឹង ឬញត្តិ ហើយដោះស្រាយបញ្ហាបរិស្ថាន និងសង្គម ដែលពាក់ព័ន្ធ តាមពេលវេលាកំណត់សមស្រប និងផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធតាមស្ថានភាពជាក់ស្តែង ។

បែបបទ និងនីតិវិធីនៃការដោះស្រាយបណ្តឹង ឬញត្តិនេះត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៤៥._**

គម្រោងនានាដែលត្រូវបានកំណត់នៅក្នុងប្រកាសស្តីពីបញ្ជីនៃគម្រោង ដែលតម្រូវឱ្យមានការធ្វើសវនកម្មបរិស្ថានខាងក្រៅ ត្រូវធ្វើសវនកម្មដោយសវនករបរិស្ថានខាងក្រៅ ដែលមានលក្ខណៈសម្បត្តិដូចមានចែងក្នុងប្រកាសស្តីពីការធ្វើសវនកម្មបរិស្ថានខាងក្រៅ ។

សវនករបរិស្ថានខាងក្រៅ មានតួនាទី និងភារៈកិច្ច ជាអាទិ៍៖

-ជួយជ្រោមជ្រែងក្នុងការកត់ត្រាកំណត់ត្រាបរិស្ថានឲ្យបានត្រឹមត្រូវនិងពេញលេញ។

-ផ្តល់មតិយោបល់សវនកម្មវិជ្ជាជីវៈ ជាអាទិ៍ របាយការណ៍បរិស្ថានដែលបង្ហាញនូវទិដ្ឋភាពពេញលេញ និងសមស្របអំពីការគ្រប់គ្រងបរិស្ថាននៃគម្រោង ឬការប្រតិបត្តិការរបស់គម្រោង ។

-ពិនិត្យភាពគ្រប់គ្រាន់នៃការអនុវត្ត នីតិវិធីនៃការគ្រប់គ្រង និងការអង្កេតតាមដានបរិស្ថានផ្ទៃក្នុង ព្រមទាំងការផ្តល់អនុសាសន៍ដើម្បីកែលម្អ ។

-ផ្តល់ព័ត៌មានអំពីភាពមិនប្រក្រតី និងការខ្វះចន្លោះក្នុងការគ្រប់គ្រងបរិស្ថានផ្ទៃក្នុងរបស់ខ្លួន ។

សំណៅមួយច្បាប់នៃរបាយការណ៍សវនកម្ម ដែលធ្វើឡើងដោយសវនករបរិស្ថានខាងក្រៅ ត្រូវប្រគល់ជូនក្រសួងបរិស្ថាន ។

**មាត្រា ៤៦._**

គម្រោងអភិវឌ្ឍន៍នីមួយៗត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោង ដូចតទៅ៖

-របាយការណ៍រៀងរាល់ ០៣ (បី) ខែ ដែលរាយកាណ៍ពីលទ្ធផលទាំងអស់នៃការអង្កេតតាមដាន និងការគ្រប់គ្រងបរិស្ថាន ដែលត្រូវបញ្ជូនទៅអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

-ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីបញ្ចប់ឆ្នាំហិរញ្ញវត្ថុនីមួយៗ ម្ចាស់គម្រោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ប្រចាំឆ្នាំ ដែលដាក់បញ្ចូលមតិយោបល់របស់សវនករស្តីពីបរិស្ថាន

-ផ្តល់សំណៅរបាយការណ៍បរិស្ថានប្រចាំឆ្នាំ នៃគម្រោងដល់សាធារណជន តាមការស្នើសុំដោយឥតគិតថ្លៃ

-ផ្តល់សំណៅអេឡិចត្រូនិក ដែលត្រូវបង្ហោះលើគេហទំព័រជាសាធារណៈ របស់ក្រសួងបរិស្ថាន និងដោយម្ចាស់គម្រោង នៅលើគេហទំព័រសាធារណៈមួយ ។

**មាត្រា ៤៧._**

គម្រោងអភិវឌ្ឍន៍ ដែលមានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបញ្ជូនរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆមាស ទៅអង្គភាពវាយតម្លៃហេតុប៉ះពាល់ បរិស្ថានទាក់ទងនឹងការអង្កេតតាមដាន និងការគ្រប់គ្រងបរិស្ថានរបស់ខ្លួន ។

ម្ចាស់គម្រោងមានកាតព្វកិច្ចត្រូវរាយការណ៍ភ្លាមៗ អំពីបញ្ហាបរិស្ថានសំខាន់ដល់អាជ្ញាធរដែលពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច និងដល់សាធារណជន ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន ឬសង្គម ។

ម្ចាស់គម្រោង ត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាននៃគម្រោង ដល់ក្រសួងបរិស្ថាន តាមការស្នើសុំរបស់ក្រសួងបរិស្ថាន ។

# ជំពូកទី ៧
# ការវាយតម្លៃបរិស្ថានយុទ្ធសាស្ត្រ និងផលប៉ះពាល់ឆ្លងដែន
## ផ្នែកទី ១
## ការវាយតម្លៃបរិស្ថានយុទ្ធសាស្ត្រ

**មាត្រា ៤៨._**

ក្រសួងបរិស្ថានត្រូវទទួលខុសត្រូវក្នុងការពិនិត្យ និងវាយតម្លៃបរិស្ថានយុទ្ធសាស្ត្រតាមវិស័យទៅលើគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល ព្រមទាំងពិនិត្យមតិយោបល់ដែលទទួលបានមកពីភ្នាក់ងារពាក់ព័ន្ធ និងពីសាធារណជន ។

វិស័យអភិវឌ្ឍន៍សំខាន់ៗ ដែលតម្រូវឱ្យមានការវាយតម្លៃបរិស្ថានយុទ្ធសាស្ត្រ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ក្រសួងបរិស្ថានត្រូវបង្កើតគោលការណ៍ណែនាំ សម្រាប់ការវាយតម្លៃបរិស្ថានយុទ្ធសាស្ត្រនេះ ។

## ផ្នែកទី២
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន

### មាត្រា ៤៩._

គម្រោងដែលអាចមានផលប៉ះពាល់បរិស្ថានឆ្លងដែន ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ។

ក្រសួងបរិស្ថាន ត្រូវបង្កើតគោលការណ៍ណែនាំ ស្តីពីលក្ខណវិនិច្ឆ័យកំណត់ពីសញ្ញាណនៃផលប៉ះពាល់បរិស្ថានឆ្លងដែន និងឈានទៅដល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ។

បែបបទ និងនីតិវិធី នៃការអនុវត្តការវាយតម្លៃហេតុប៉ះពាល់ឆ្លងដែន ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៨
## ថ្លៃសេវា និងបន្ទុកផ្សេងៗ

### មាត្រា ៥០._

ម្ចាស់គម្រោង ត្រូវទទួលរ៉ាប់រងបង់រាល់ការចំណាយទាំងអស់ ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ សេវាសម្រាប់ចាត់ថ្នាក់គម្រោង សេវាសម្រាប់កំណត់លើវិសាលភាពនៃការសិក្សា និងក្នុងការចំណាយលើកិច្ចដំណើរការចូលរួមជាសាធារណៈ សេវាសម្រាប់ការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍របស់ក្រសួងបរិស្ថាន សេវាពិនិត្យរបាយការណ៍អង្កេតតាមដានបរិស្ថាន រួមទាំងគណៈកម្មការត្រួតពិនិត្យជំនាញ ។

### មាត្រា ៥១

ម្ចាស់គម្រោងត្រូវទទួលរ៉ាប់រង ក្នុងការបង់ថ្លៃចំណាយលើការរៀបចំ និងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងផែនការអង្កេតតាមដានបរិស្ថាន និងថ្លៃចំណាយលើការអនុវត្ត និងការអង្កេតតាមដានវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គម ដូចមានចែងក្នុងផែនការគ្រប់គ្រង បរិស្ថាន និងផែនការអភិវឌ្ឍន៍សង្គម ។

### មាត្រា ៥២

ថវិកាលំអិតអំពីការប៉ាន់ស្មាននៃការចំណាយ លើវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថានដែលត្រូវដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង។

ថ្លៃចំណាយលើការផ្សព្វផ្សាយឯកសារជាសាធារណៈ រាប់ទាំងគេហទំព័រ ដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង ។

ថ្លៃចំណាយទាំងអស់ក្នុងការកែតម្រូវ ឬកែលម្អវិធានការកាត់បន្ថយផលប៉ះពាល់ និងកម្មវិធីអង្កេតតាមដានគម្រោង ដូចមានចែងក្នុងមាត្រា ៤៣ នៃច្បាប់នេះ ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង។

ថ្លៃចំណាយទាំងអស់ ក្នុងការដោះស្រាយវិវាទពាក់ព័ន្ធនឹង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ទាំងតាមប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ ដូចមានចែងក្នុងមាត្រា ៦៥ នៃច្បាប់នេះ ជាបន្ទុករបស់ម្ចាស់គម្រោង ។

ថ្លៃសេវា និងបន្ទុកផ្សេងៗ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៥៣._**

នៅពេលម្ចាស់គម្រោងដាក់ពាក្យសុំពិនិត្យ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ក្រសួងបរិស្ថានមានភារកិច្ចប្រមូលថ្លៃ និងបន្ទុកសេវា ដូចមានចែងនៅក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង់ថ្លៃសេវាការងារសម្រាប់ការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា ៥៤._**

ម្ចាស់គម្រោងត្រូវបង់សេវាពិនិត្យលើរបាយការណ៍អង្កេតតាមដានបរិស្ថានទៅឱ្យក្រសួងបរិស្ថាន ដើម្បីប្រើប្រាស់សម្រាប់ការកសាងសមត្ថភាព ដល់មន្ត្រីបរិស្ថាន និងដើម្បីផ្តល់លទ្ធភាពដល់ក្រសួងបរិស្ថានក្នុងការអនុវត្តតួនាទីរបស់ខ្លួន ក្នុងការត្រួតពិនិត្យរបាយការណ៍តាមដានត្រួតពិនិត្យ ក៏ដូចជាឆ្លើយតបចំពោះ សំណើឱ្យមានការស៊ើបអង្កេតលើបណ្តឹងបរិស្ថាន និងក្នុងការអនុវត្តការតាមដានត្រួតពិនិត្យ លើការអនុលោមតាមច្បាប់ជាប្រចាំ ទាំងនៅក្នុងអំឡុងពេលនៃដំណាក់សាងសង់ និងដំណាក់កាលប្រតិបត្តិការគម្រោង ។

**មាត្រា ៥៥._**

ម្ចាស់គម្រោងត្រូវបង់មូលនិធិបរិស្ថាន និងសង្គម ដល់ក្រសួងបរិស្ថានជាអប្បរមា ១ (មួយ) ភាគរយនៃថ្លៃគម្រោងវិនិយោគ។

មូលនិធិបរិស្ថាន និងសង្គមត្រូវបានបង្កើតឡើងដោយក្រសួងបរិស្ថាន ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការស្តារបរិស្ថាន អភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍន៍សង្គមនៅក្នុង និងជុំវិញតំបន់ដែលគម្រោងតាំងនៅ ។ មូលនិធិបរិស្ថាន និងសង្គម ត្រូវគ្រប់គ្រងដោយក្រសួងបរិស្ថាន តាមការកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៥៦._**

ម្ចាស់គម្រោងត្រូវបង់មូលនិធិទាយជ្ជទានបរិស្ថាន តាមការព្រមព្រៀងគ្នារវាងក្រសួងបរិស្ថាន និងម្ចាស់គម្រោង ជារៀងរាល់ឆ្នាំរហូតដល់បញ្ចប់អាជីវកម្ម ដោយផ្អែកលើប្រភេទ និងទំហំនៃគម្រោងអភិវឌ្ឍន៍។

**មាត្រា ៥៧._**

ក្រសួងបរិស្ថាន មន្ទីរបរិស្ថានរាជធានី ខេត្ត និងភ្នាក់ងារទទួលខុសត្រូវបរិស្ថាន និងរដ្ឋបាលមូលដ្ឋាន មានសិទ្ធិធ្វើសំណើសុំរង្វាន់ ឬវិញ្ញាបនបត្រលើកទឹកចិត្ត ឬលិខិតទទួលស្គាល់ដទៃទៀតចំពោះសមិទ្ធផល ដែលសម្រេចបាននូវកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងប្រទេសកម្ពុជា ឲ្យទៅបុគ្គល អង្គភាព ក្រុមហ៊ុន ឬអង្គការណាមួយដែលមានស្នាដៃឆ្នើមក្នុងសកម្មភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

# ជំពូកទី ៩
# មន្ត្រីនគរបាលយុត្តិធម៌

**មាត្រា ៥៨._**

សមាសភាពមន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃហេតុប៉ះពាល់បរិស្ថានមានៈ

-មន្ត្រីនៃអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

-មន្ត្រីនៃមន្ទីរបរិស្ថានរាជធានី/ខេត្ត

ដើម្បីទទួលបាននីតិសម្បទា ជាមន្ត្រីនគរបាលយុត្តិធម៌ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន ត្រូវធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍។ សម្បថមិនចាំបាច់ធ្វើជាថ្មីម្តងទៀតឡើយ នៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នៅពេលក្រោយទៀត ។

បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌ ។ ចំពោះរូបមន្តនៃពាក្យសម្បថ ត្រូវកំណត់ដោយក្រសួងយុត្តិធម៌ ។

**មាត្រា ៥៩._**

មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចក្នុងការ ទទួលពាក្យបណ្តឹង ត្រួតពិនិត្យបទល្មើស ធ្វើការស៊ើបអង្កេត បង្ក្រាបបទល្មើស និងកសាងសំណុំរឿងដែលពាក់ព័ន្ធនឹង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីប្តឹងទៅតុលាការមានសមត្ថកិច្ច ។

ប្រតិបត្តិការ របស់មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ៦០._**

មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសមត្ថកិច្ចដែនដីទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នៃមន្ទីរបរិស្ថានរាជធានី /ខេត្ត មានសមត្ថកិច្ចដែនដីនៅក្នុងមណ្ឌលរដ្ឋបាលរបស់ខ្លួន ។

ក្នុងករណីមានវិវាទសមត្ថកិច្ច ឬជាន់សមត្ថកិច្ចដែនដី រដ្ឋមន្ត្រីនៃក្រសួងបរិស្ថានជាអ្នកសម្រេច ។

ការសម្រេចនេះបិទផ្លូវតវ៉ា ។

**មាត្រា ៦១._**

អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ត្រូវបង្កភាពងាយស្រួល និងជួយផ្តល់កម្លាំងសហការក្នុងការស្រាវជ្រាវ ត្រួតពិនិត្យបទល្មើស និងបង្ក្រាប

បទល្មើសវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងករណីមានការស្នើសុំ ពីមន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ។

**មាត្រា ៦២._**

នីតិវិធីកសាងសំណុំរឿងរបស់មន្ត្រីនគរបាលយុត្តិធម៌ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។ ទម្រង់ និងបែបបទនៃការធ្វើកំណត់ហេតុបទល្មើសការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌ ។

**មាត្រា ៦៣._**

មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានប័ណ្ណសម្គាល់អត្តសញ្ញាណច្បាស់លាស់ នៅពេលចុះបំពេញបេសកកម្មក្នុងនាមជា មន្ត្រីនគរបាលយុត្តិធម៌ ។

## ជំពូកទី ១០
## ការដោះស្រាយវិវាទវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា ៦៤._**

បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវរាយការណ៍ អំពីបទល្មើសដែលពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មកអាជ្ញាធរមូលដ្ឋាន ឃុំ/សង្កាត់ ឬស្រុក/ខណ្ឌ ឬខេត្ត/រាជធានី ឬមន្ទីរបរិស្ថានរាជធានី/ខេត្ត ឬអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន ។

បន្ទាប់ពីបានទទួលសេចក្តីរាយការណ៍ អាជ្ញាធរមូលដ្ឋានត្រូវរាយការណ៍បន្តជូន មន្ទីរបរិស្ថានរាជធានី/ខេត្ត ឬអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថានយ៉ាងយូរបំផុត ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសេចក្តីរាយការណ៍នោះ ។ ក្រោយពីបានទទួលសេចក្តីរាយការណ៍ មន្ទីរបរិស្ថានខេត្ត/រាជធានី ឬអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវធ្វើការស៊ើបអង្កេត និងចំណាត់ការ លើសេចក្តីរាយការណ៍នោះ ។

**មាត្រា ៦៥._**

នៅពេលដែលភាគីទទួលរងផលប៉ះពាល់ ដោយសារបទល្មើសដែលពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានប្តឹងតវ៉ាមកម្ចាស់គម្រោង ម្ចាស់គម្រោងត្រូវធ្វើការដោះស្រាយវិវាទនេះអោយចប់សព្វគ្រប់ក្នុងអំឡុងពេល យ៉ាងយូរបំផុត ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

ក្នុងករណីដែលភាគីរងផលប៉ះពាល់មិនពេញចិត្តនឹងដំណោះស្រាយរបស់ម្ចាស់គម្រោង ភាគីដែលរងផលប៉ះពាល់អាចប្តឹងជំទាស់ទៅ មន្ទីរបរិស្ថានរាជធានី/ខេត្ត ឬអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃទទួលបានសេចក្តីសម្រេចរបស់ម្ចាស់គម្រោង។ មន្ទីរបរិស្ថានរាជធានី ខេត្ត ឬអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវសម្រេចលើបណ្តឹងជំទាស់ក្នុងរយៈពេល ៣០ (សាបសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្តឹងជំទាស់នោះ ។

ប៉ុន្តែនៅពេលដែលភាគីណាមួយ មិនពេញចិត្តនឹងសេចក្តីសម្រេច ឬដំណោះស្រាយរបស់មន្ទីរបរិស្ថានរាជធានី/ខេត្ត ឬអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ភាគីនោះអាចប្តឹងជំទាស់បន្តមករដ្ឋមន្ត្រីក្រសួងបរិស្ថានក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានដំណោះស្រាយ ឬសេចក្តីសម្រេចនេះ ។

រដ្ឋមន្ត្រីនៃក្រសួងបរិស្ថានមានរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃនៃថ្ងៃធ្វើការដើម្បីធ្វើការដោះស្រាយបណ្តឹងជំទាស់នេះ ។ ក្នុងករណីដែលភាគីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីនៃក្រសួងបរិស្ថាន ភាគីអាចប្តឹងជំទាស់បន្តទៀតមកតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានដំណោះស្រាយ ឬសេចក្តីសម្រេចនេះ។

តុលាការត្រូវធ្វើការសម្រេចលើពាក្យបណ្តឹងជំទាស់ខាងលើនេះ ក្នុងរយៈពេល ៣ (បី) ខែ គិតពីថ្ងៃទទួលបានពាក្យបណ្តឹងជំទាស់ខាងលើនេះ ។ ភាគីដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាដំបូង អាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចរបស់សាលាដំបូង ។ សាលាឧទ្ធរណ៍ជាតុលាការចុងក្រោយ ដែលត្រូវសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ។ សេចក្តីសម្រេចនេះជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

**មាត្រា ៦៦._**

ម្ចាស់គម្រោង ត្រូវមានសៀវភៅកំណត់ត្រាពាក្យបណ្តឹង ដែលអនុលោមទៅតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថាន ឬស្ថាប័នតុលាការអាចពិនិត្យសៀវភៅកំណត់ត្រា ពាក្យបណ្តឹងនេះគ្រប់ពេលវេលា ។

**មាត្រា ៦៧._**

វិវាទពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវតែធ្វើការដោះស្រាយតាមយន្តការសម្របសម្រួលរបស់ក្រសួងបរិស្ថានជាមុនសិន មុននឹងឈានដល់ការដោះស្រាយតាមប្រព័ន្ធតុលាការ លើកលែងតែវិវាទនេះមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌដែលជាសមត្ថកិច្ចរបស់តុលាការ ។

បែបបទ និងនីតិវិធីក្នុងការដោះស្រាយវិវាទ ពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦៨._**

ក្នុងករណីដែលមានវិវាទនឹងសេចក្តីសម្រេចផ្លូវរដ្ឋបាល ដែលពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលចេញដោយមន្ទីរបរិស្ថានរាជធានី/ខេត្ត ឬអង្គភាពវាយតម្លៃហេតុប៉ះពាល់ បរិស្ថាន ភាគីដែលមិនសុខចិត្តនឹងសេចក្តីរដ្ឋបាលនោះអាចប្តឹងតវ៉ាទៅរដ្ឋមន្ត្រីនៃក្រសួងបរិស្ថាន ក្នុង រយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចនោះ ។

រដ្ឋមន្ត្រីនៃក្រសួងបរិស្ថានត្រូវសម្រេចលើបណ្តឹងតវ៉ានោះក្នុងរយៈពេល ៤៥ (សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលទទួលបានពាក្យបណ្តឹង ។

ក្នុងករណីដែលមិនសុខចិត្តនឹង សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីនៃក្រសួងបរិស្ថាន ភាគីអាចប្តឹងជំទាស់បន្តទៅតុលាការ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចនោះ។

តុលាការត្រូវធ្វើការសម្រេចលើពាក្យបណ្ដឹងជំទាស់ខាងលើនេះ ក្នុងរយៈពេល ៣ (បី) ខែ គិតពីថ្ងៃទទួលបានពាក្យបណ្ដឹងជំទាស់ខាងលើនេះ ។

**មាត្រា ៦៩._**

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី/ខេត្ត មានសិទ្ធិប្ដឹង ឬចូលរួមក្នុងដំណើរការនៃការទាមទារសំណងលើការខូចខាតបរិស្ថាន និងសង្គម ដែលកើតចេញពីបទល្មើសពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងដំណាក់កាលតុលាការ ។

ក្នុងករណីដែលមន្ទីរបរិស្ថានរាជធានី/ខេត្ត ពុំមានលទ្ធភាពធ្វើការគណនាពីបរិមាណនៃសំណងការខូចខាតនោះ មន្ទីរបរិស្ថានរាជធានី/ខេត្តអាចធ្វើការស្នើសុំជំនួយពីក្រសួងបរិស្ថាន ។

ការចាត់ចែងប្រាក់សំណងការខូចខាតតាមរយៈសាលក្រម ឬសាលដីកាស្ថាពរ ក្នុងការស្ដារការខូចខាតបរិស្ថាន និងសង្គមឡើងវិញ ជាសមត្ថកិច្ចរបស់អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងមន្ទីរបរិស្ថានរាជធានី/ខេត្ត ។

# ជំពូកទី ១១
# ទោសប្បញ្ញត្តិ

**មាត្រា ៧០._**

ទណ្ឌកម្មដែលមានក្នុងច្បាប់នេះរួមមាន ទណ្ឌកម្មវិន័យខាងរដ្ឋបាល ទោសពិន័យអន្តរការណ៍ និងទោសព្រហ្មទណ្ឌ ។

ទណ្ឌកម្មវិន័យខាងរដ្ឋបាលមានជាអាទិ៍ ការព្រមាន ការព្យួរការងារ ការដកហូតពីតួនាទី ឬមុខតំណែង និងបញ្ឈប់ពីក្របខណ្ឌការងារ ។

ទោសពិន័យអន្តរការណ៍ គឺជាការបង់ប្រាក់ពិន័យដែលជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថានជាអ្នកប្រមូល ។ ទោសពិន័យអន្តរការណ៍អាចអនុវត្តបានក្នុងករណីដែលជនល្មើសទទួលស្គាល់កំហុស និងយល់ព្រមបង់ប្រាក់ពិន័យ ។ ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរលត់បណ្ដឹងអាជ្ញា ។

នីតិវិធីនៃការកំណត់ និងការបង់ប្រាក់ពិន័យអន្តរការណ៍ត្រូវកំណត់ដោយក្រសួងបរិស្ថាន ។ ប្រាក់ពិន័យអន្តរការណ៍ត្រូវបង់ចូលថវិការជាតិ ប៉ុន្តែរាជរដ្ឋាភិបាលអាចសម្រេចផ្ដល់ប្រាក់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងការបង្ក្រាបបទល្មើសតាមសំណើររបស់ក្រសួងបរិស្ថាន ។

ក្នុងករណីដែលម្ចាស់គម្រោង មិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍តាមការកំណត់ ក្រសួងបរិស្ថាន អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី/ខេត្ត អាចប្ដឹងទៅតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

ទោសព្រហ្មទណ្ឌមានជាអាទិ៍ ទោសពន្ធនាគារ ទោសពិន័យជាប្រាក់ និងទោសបន្ថែម។

បុគ្គលដែលទទួលទោសទណ្ឌខាងលើនេះ មិនអាចរួចផុតពីការទទួលខុសត្រូវ លើសំណងការខូចខាត និងសំណងជម្ងឺចិត្ត និងការជួសជុលការខូចខាតបរិស្ថានឡើងវិញបានឡើយ ក្នុងករណីដែលមានបណ្ដឹងទាមទារ ។

**មាត្រា ៧១._**

ការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ទោសពិន័យជាប្រាក់ ទោសបន្ថែម ការរឹបអូសវត្ថុតាងសំណងការខូចខាត ការជួសជុល ការស្តារការខូចខាតបរិស្ថានឡើងវិញជាសមត្ថកិច្ចរបស់តុលាការ ។

ការសម្រេចពិន័យអន្តរការណ៍ ជាការព្រមាន ការកែតម្រូវ ការចាប់យកវត្ថុតាងនៃបទល្មើស និងការបង់ប្រាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានីខេត្ត ។

ចំពោះទោសទណ្ឌជាការជួសជុល ការស្តារការខូចខាត ការព្យួរជាបណ្តោះអាសន្ន ការលុបលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រឯកភាពលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការលុបចោល កិច្ចសន្យា ឬការបង់ប្រាក់ពិន័យអន្តរការណ៍ ឬផ្អាកសកម្មភាពគម្រោង ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៧២._**

អាជ្ញាយុកាលនៃបទល្មើសពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុលោមទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌដែលមានជាធរមាន ។

បទល្មើសពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជាប្រភេទបទល្មើសនិរន្ត ដែលអាជ្ញាយុកាលនៃបទល្មើសត្រូវគិតចាប់ពីថ្ងៃរកឃើញបទល្មើស ។

**មាត្រា ៧៣._**

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ចំពោះបុគ្គលិកណាដែលមានចេតនាមិនសហការ មិនអនុញ្ញាត ឬគេចវេស ក្នុងការអនុញ្ញាតឲ្យមន្ត្រី នៃអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានចូលធ្វើអធិការកិច្ច តាមបញ្ញត្តិនៃមាត្រា ១២ នៃច្បាប់នេះ ។

ក្នុងករណីដែលអំពើនោះធ្វើឲ្យប៉ះពាល់ដល់បូរណភាពរាងកាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ០៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ។

ក្នុងករណីអំពើនោះបណ្តាលឱ្យបាត់បង់ជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ដល់ជនរងគ្រោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៧៤._**

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ចំពោះម្ចាស់គម្រោង បុគ្គលដែលមានសិទ្ធអំណាចកក្នុងការសម្រេច បុគ្គលដែលមានអំណាច បង្ខំឱ្យបុគ្គលិក ឬអ្នកនៅក្រោមឱវាទរបស់ខ្លួនធ្វើការរារាំង ឬមិនអនុញ្ញាតឱ្យមន្ត្រីនៃអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចូលធ្វើអធិការកិច្ច តាមបញ្ញត្តិនៃមាត្រា ១២ នៃច្បាប់នេះ ។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ។

ក្នុងករណីដែលអំពើនោះធ្វើឲ្យប៉ះពាល់ដល់បូរណភាពរាងកាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ០៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ។

ក្នុងករណីអំពើនោះបណ្តាលឱ្យបាត់បង់ជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ដល់ជនរងគ្រោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៧៥._**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរពីមន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចំពោះម្ចាស់គម្រោងទាំងឡាយណាដែលមិនអនុវត្តតាមល័ក្ខខ័ណ្ឌតម្រូវ ដូចមានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ដូចមានចែងក្នុងមាត្រា ៤២ នៃច្បាប់នេះ ។ ក្នុងករណីមិនរាងចាលត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬផ្អាកសកម្មភាពគម្រោង ។

ក្នុងករណីដែលមិនគោរពល័ក្ខខ័ណ្ឌខាងលើ ហើយបណ្តាលឱ្យបាត់បង់ជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ម្ចាស់គម្រោង ត្រូវទទួលការផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ៣០.០០០.០០០ (សាមសិបលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ។

ក្នុងករណីដែលមិនគោរពល័ក្ខខ័ណ្ឌខាងលើ ហើយធ្វើឲ្យប៉ះពាល់ដល់ជីវិតសត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន និងសង្គម ម្ចាស់គម្រោងត្រូវសងសំណងខូចខាតតាមសមាមាត្រនឹងទំហំនៃការខូចខាត ។

នីតិបុគ្គលអាចត្រូវប្រកាសឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ តាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ និងត្រូវពិន័យជាប្រាក់ពី ៥០.០០០.០០០ (ហាសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល ។

**មាត្រា ៧៦._**

ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាល ចំពោះមន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃហេតុប៉ះពាល់បរិស្ថានណា ដែលប្រព្រឹត្តបំពាន ឬមិនបំពេញតួនាទីរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ១២ និងមាត្រា ៥៩ នៃច្បាប់នេះ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

**មាត្រា ៧៧._**

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល និង/ឬ ដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៣ (បី) ឆ្នាំ និងត្រូវជួសជុល ស្តារការខូចខាត ដែលបានបង្កឡើង ចំពោះម្ចាស់គម្រោងដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ២៨ នៃច្បាប់នេះ ។ ការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌខាងលើដោយអយ្យការ ត្រូវធ្វើឡើងតាមបណ្តឹងពីក្រសួងបរិស្ថាន ។

ក្នុងករណីដែលគម្រោងមិនទាន់មានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ បង្កផលប៉ះពាល់ជាអវិជ្ជមាន ដល់ មនុស្ស សត្វ ទ្រព្យសម្បត្តិ បរិស្ថាន និងសង្គម ម្ចាស់គម្រោងត្រូវទទួលទណ្ឌកម្មពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល និងត្រូវសងសំណងខូចខាត ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

ក្រៅពីទណ្ឌកម្មខាងលើ ម្ចាស់គម្រោងអាចទទួលរងទណ្ឌកម្ម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងទោសបន្ថែមដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៧៨._**

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល និង/ឬដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៣ (បី) ឆ្នាំ និងត្រូវជួសជុល ស្តារការខូចខាត ដែលបានបង្កឡើង ចំពោះម្ចាស់គម្រោងដែលមានស្រាប់ ឬកំពុងដំណើរការដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៣១ នៃច្បាប់នេះ ចាប់ពីច្បាប់នេះចូលជាធរមាន ។ ការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌខាងលើដោយអយ្យការ ត្រូវធ្វើឡើងតាមបណ្តឹងពីក្រសួងបរិស្ថាន ។

ក្នុងករណីដែលគម្រោងមិនទាន់មានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ បង្កផលប៉ះពាល់ជាអវិជ្ជមាន ដល់ មនុស្ស សត្វ ទ្រព្យសម្បត្តិ បរិស្ថាន និងសង្គម ម្ចាស់គម្រោងត្រូវទទួលទណ្ឌកម្មពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល និងត្រូវសងសំណងខូចខាត ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

ក្រៅពីទណ្ឌកម្មខាងលើ ម្ចាស់គម្រោងអាចទទួលរងទណ្ឌកម្ម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងទោសបន្ថែមដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៧៩._**

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះម្ចាស់គម្រោងដែលមិនបានអនុវត្តការជូនដំណឹងដូចមានចែងក្នុងមាត្រា ១៥ នៃច្បាប់នេះ ។

**មាត្រា ៨០._**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ៣០.០០០.០០០ (សាបសិបលាន) រៀល ទៅ ៦០.០០០.០០០ (ហុកសិបលាន) រៀល ចំពោះម្ចាស់គម្រោងដែលបានប្រព្រឹត្តអំពើក្លែងបន្លំទិន្នន័យ ឬលួចចម្លងទិន្នន័យអ្នកដទៃ ក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និង/ឬ ពេញលេញ ដើម្បីទទួលបាននូវលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ ពេញលេញ ។

**មាត្រា ៨១._**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ៣០.០០០.០០០ (សាបសិបលាន) រៀល ទៅ ៦០.០០០.០០០ (ហុកសិបលាន) រៀល ចំពោះក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬអ្នកជំនាញការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានចុះបញ្ជីស្របច្បាប់ ដែលទទួលស្គាល់ដោយក្រសួងបរិស្ថាន ដែលបានប្រព្រឹត្តអំពើក្លែងបន្លំទិន្នន័យ ឬលួចចម្លងទិន្នន័យអ្នកដទៃក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និង/ឬ ពេញលេញ ។

ទោសបន្ថែមដែលអាចត្រូវប្រកាស មានជាអាទិ៍ ការផ្អាកមិនឱ្យប្រកបវិជ្ជាជីវៈរយៈពេល ៥ (ប្រាំ) ឆ្នាំ ការលុបឈ្មោះពីបញ្ជីអ្នកជំនាញធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារពត៌មានជាសាធារណៈថ្នាក់ជាតិ និង/ឬ ថ្នាក់តំបន់ ។

**មាត្រា ៨២._**

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ ពី ៣០.០០០.០០០ (សាបសិបលាន) រៀល ទៅ ៦០.០០០.០០០ (ហុកសិបលាន) រៀល ចំពោះក្រុមហ៊ុនទីប្រក្សា ឬអ្នកជំនាញការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលប្រកបវិជ្ជាជីវៈយកកម្រៃ ហើយពុំទាន់បានចុះបញ្ជី ឬទទួលស្គាល់ដោយក្រសួងបរិស្ថាន ។

ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ៦០.០០០.០០០(ហុកសិបលាន) រៀល ដល់ ១០០.០០០.០០០ (មួយរយលាន) រៀល ។

**មាត្រា ៨៣._**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ ឬពិន័យអន្តរការណ៍ជាប្រាក់ពី ៣០.០០០.០០០ (សាបសិបលាន) រៀល ទៅ ៦០.០០០.០០០ (ហុកសិបលាន) រៀល ចំពោះក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬអ្នកជំនាញការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលការចុះបញ្ជីរបស់ខ្លួនត្រូវបានព្យួរតាមសេចក្តីសម្រេចរបស់ក្រសួងបរិស្ថាន ហើយនៅតែបន្តប្រកបវិជ្ជាជីវៈវាយតម្លៃហេតុប៉ះពាល់បរិស្ថានយកកម្រៃទៀត ។ ការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌខាងលើដោយអយ្យការ ត្រូវធ្វើឡើងតាមបណ្តឹងពីក្រសួងបរិស្ថាន ។

**មាត្រា ៨៤._**

ម្ចាស់គម្រោង ត្រូវទទួលរងការព្រមានជាលាយលក្ខណ៍អក្សរពីក្រសួងបរិស្ថាន ចំពោះការមិនគោរព ឬបំពានលើកិច្ចសន្យាការពារបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា ១៨ ។ ក្នុងករណីមិនរាងចាលត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ។

ម្ចាស់គម្រោងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ៣០.០០០.០០០ (សាមសិបលាន) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះការ មិនគោរពកិច្ចសន្យាការពារបរិស្ថាន ហើយដែលការអនុវត្តគម្រោងនោះធ្វើឱ្យប៉ះពាល់ដល់ជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ដល់ជនរងគ្រោះ។

ក្នុងករណីសកម្មភាព ឬគម្រោងខាងលើនោះ បង្កឱ្យប៉ះពាល់ដល់ជីវិតសត្វ ទ្រព្យសម្បត្តិ ឬបរិស្ថាន និងសង្គម ម្ចាស់គម្រោងត្រូវសងសំណងខូចខាតឱ្យសមាមាត្រទៅនឹងទំហំនៃការខូចខាត ។

**មាត្រា ៨៥._**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ ចំពោះមន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មន្ត្រីនៃមន្ទីរបរិស្ថានរាជធានី ខេត្ត និងមន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធ ដែលបានឃុបឃិត ឬជួយសម្រួល រៀបចំឯកសារ ឬធ្វើរបាយការណ៍ដែលមិនពិត ដោយចេតនា ដែលនាំឱ្យ

ទទួលបានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ពីថ្នាក់ដឹកនាំក្រសួងបរិស្ថាន។

**មាត្រា ៨៦._**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល ចំពោះមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ឬពលរដ្ឋទទួលអាណត្តិដោយការបោះឆ្នោត ដែលរំលោភលើសិទ្ធិនិងអំណាចរបស់ខ្លួនប្រព្រឹត្តអំពើ ជាអាទិ៍ ការសម្រួល ការធ្វើអន្តរាគមន៍ ការបិទបាំង ការរារាំង ឬការសមគំនិតជាមួយនឹងចារី ដើម្បីឧបត្ថម្ភគាំពារគម្រោងដែលមិនមានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឱ្យគម្រោងដំណើរការទៅដោយខុសច្បាប់ ។

**មាត្រា ៨៧._**

ម្ចាស់គម្រោង ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរដោយបង្គាប់ឱ្យបង់មូលនិធិបរិស្ថាន និងសង្គម ចំពោះការខកខានមិនបានបង់ប្រាក់ចូលមូលនិធិដូចមានកំណត់នៅក្នុងមាត្រា ៥៥ និងការខកខានមិនបានបង់មូលនិធិទាយជ្ជទានដូចមានចែងនៅក្នុងមាត្រា ៥៦ នៃច្បាប់នេះ ដោយក្រសួងបរិស្ថាន ។ នៅក្នុងករណីដែលម្ចាស់គម្រោងមិនបានបង់ប្រាក់ ក្រោយពីទទួលការព្រមាននេះ ម្ចាស់គម្រោងត្រូវទទួលទណ្ឌកម្មជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ រួមទាំងពិន័យជាប្រាក់ចំនួន ៣ (បី) ដង នៃចំនួនទឹកប្រាក់ដែលត្រូវបង់ចូលមូលនិធិបរិស្ថាន និងសង្គម និងមូលនិធិទាយជ្ជទានបរិស្ថាន តាមបញ្ញត្តិមាត្រា ៥៥ និង ៥៦ នៃច្បាប់នេះ ។

**មាត្រា ៨៨._**

ម្ចាស់គម្រោងត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ដោយបង្គាប់ឱ្យរៀបចំរបាយការណ៍អង្កេតតាមដានគម្រោង និងបញ្ជូនមកក្រសួងបរិស្ថាន ដូចមានកំណត់ក្នុងមាត្រា ៤៦ និងមាត្រា ៤៧ នៃច្បាប់នេះ ។ ក្នុងករណីដែលម្ចាស់គម្រោងមិនបានរៀបចំ និងបញ្ជូនរបាយការណ៍មកក្រសួងបរិស្ថាន ក្រោយពីទទួលការព្រមាននេះទេ ម្ចាស់គម្រោងត្រូវទទួលទណ្ឌកម្មជាការពិន័យអន្តរការណ៍ ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល ឬ ផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ ។

**មាត្រា ៨៩._**

ក្នុងករណីដែលម្ចាស់គម្រោង មិនបង់ប្រាក់ចំណាយទាំងអស់ក្នុងការដោះស្រាយវិវាទ ទាំងក្នុងប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ ដូចមានកំណត់នៅក្នុងមាត្រា ៥២ នៃច្បាប់នេះ ក្រសួងបរិស្ថានមានសិទ្ធិសម្រេចផ្អាកសកម្មភាពគម្រោងជាបណ្តោះអាសន្ន ។

# ជំពូកទី ១២
# ការអនុវត្តន៍សេចក្ដីសម្រេចតុលាការ

**មាត្រា ៩០.-**

ការអនុវត្តសេចក្ដីសម្រេចរបស់តុលាការ ដែលពាក់ព័ន្ធនឹងបទល្មើសវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវធ្វើឡើងដោយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ក្រោមការដឹកនាំ ឬការបញ្ជា របស់តុលាការ ។

**មាត្រា ៩១.-**

ក្រសួងបរិស្ថានអាចស្នើសុំថតចម្លងនូវ សេចក្ដីសម្រេចរបស់តុលាការ ដែលពាក់ព័ន្ធនឹងបទល្មើសវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា ៩២.-**

វត្ថុតាងដែលបានរឹបអូសតាមសេចក្ដីសម្រេចរបស់តុលាការ ដែលបានចូលជាស្ថាពរ ត្រូវអនុវត្តតាមនីតិវិធីព្រហ្មទណ្ឌដែលមានជាធរមាន ។

# ជំពូកទី ១៣
# អន្តរប្បញ្ញត្តិ

**មាត្រា ៩៣.-**

អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ស្ដីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលនៅជាធរមាន នៅមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមស្មារតីនៃច្បាប់នេះ ។

**មាត្រា ៩៤.-**

បទប្បញ្ញត្តិនៃមាត្រា ៣១ ដែលអនុវត្តចំពោះគម្រោងដែលមានស្រាប់ និងគម្រោងកំពុងដំណើរការទាំងអស់ត្រូវអនុវត្តរហូតដល់ពេលដែលម្ចាស់គម្រោងទាំងអស់ បានបំពេញកាតព្វកិច្ចចប់សព្វគ្រប់ ។

ទោសប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ៧៨ នៃច្បាប់នេះ មានអានុភាពអនុវត្ត នៅពេលដែលក្រសួងបរិស្ថាន កំណត់រយៈពេលតម្រូវឱ្យម្ចាស់គម្រោងធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដូចមានចែងក្នុងមាត្រា ៣១ នៃច្បាប់នេះ ។

# ជំពូកទី ១៤
# អវសានប្បញ្ញត្តិ

**មាត្រា ៩៥._**

បទប្បញ្ញត្តិនៃផ្នែកទី៣ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចំពោះការប្រែប្រួលអាកាសធាតុ នៃជំពូកទី៤ នៃច្បាប់នេះ ត្រូវយកមកអនុវត្តបន្ទាប់ពីរយៈពេល ២ ឆ្នាំ ក្រោយពីច្បាប់នេះចូលជាធរមាន ។

បទប្បញ្ញត្តិនៃផ្នែកទី២ ស្តីពីផលប៉ះពាល់បរិស្ថានឆ្លងដែន នៃជំពូកទី៧ នៃច្បាប់នេះ ត្រូវយកមកអនុវត្ត លុះត្រាតែមានកិច្ចព្រមព្រៀងទ្វេភាគី ឬសិទ្ធិសញ្ញាអន្តរជាតិស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដែលក្នុងនោះព្រះរាជាណាចក្រកម្ពុជាជាហត្ថលេខី ។

**មាត្រា ៩៦._**

១ - បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

២ - ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី........... ខែ................. ឆ្នាំ....................
ក្នុងសម័យប្រជុំរដ្ឋសភាលើកទី ...........នីតិកាលទី៥ ។

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ............ ឆ្នាំ...............

**ប្រធានរដ្ឋសភា**

ឧបសម្ព័ន្ធទី ១

# វាក្យស័ព្ទ

ច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
ច្បាប់នេះចែង និងបញ្ញត្ត អំពីការគ្រប់គ្រងលើកិច្ចដំណើរវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងព្រះរាជាណាចក្រកម្ពុជា។ រាល់សកម្មភាព ចលនា ការប្រព្រឹត្តទាំងអស់របស់បុគ្គល គ្រួសារ ម្ចាស់ទីតាំង ម្ចាស់កម្មសិទ្ធិ ទោះជារូបវន្តបុគ្គល ជានីតិបុគ្គលឯកជន ឬជានីតិបុគ្គលសាធារណៈ ជាអង្គភាព ជាក្រសួង ជាស្ថាប័នរដ្ឋ ឬជារដ្ឋនិងរដ្ឋក្តី ដែលបានធ្វើសកម្មភាពគ្រប់យ៉ាងនិងដែលបានផ្លាស់ប្តូរស្ថានភាពដើមនៃបរិស្ថាន សេដ្ឋកិច្ច សង្គម វប្បធម៌ ត្រូវគោរពអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ចំពោះសកម្មភាពដែលមានស្រាប់ ដែលកំពុងដំណើរការ ឬដែលរៀបចំចាប់ផ្តើម ។

បណ្តុំនៃផលប៉ះពាល់ : បណ្តុំនៃផលប៉ះពាល់ គឺ ជាផលប៉ះពាល់ទាំងឡាយណា ដែលកើតមក ពីផលប៉ះពាល់ចំនួនបន្ថែមរបស់គម្រោង ដែលបន្ថែមលើសកម្មភាពពី អតីតកាល បច្ចុប្បន្ន និង អនាគត ។

ការឯកភាពលើគម្រោងអភិវឌ្ឍន៍ : ជាការអនុម័ត ឬ ការអនុញ្ញាត ដែលផ្តល់អោយដោយ រដ្ឋាភិបាលកម្ពុជាសម្រាប់គម្រោង ឬ ដោយស្ថាប័នផ្សេងទៀត រួមទាំង កិច្ចសន្យាសម្បទាន ។

អ្នកទទួលផលប៉ះពាល់ផ្ទាល់: ជាអ្នកទទួលផលប៉ះពាល់ដែលមាន សិទ្ធិតទល់ ហានិភ័យ និង ការទទួលខុសត្រូវលើបញ្ហា ។ អ្នកទាំងនោះ អាចជាអ្នកដែលនៅក្នុងតំបន់ដែលគម្រោងតាំងនៅ (ឧទាហរណ៍ សហគមន៍ដែលរងផលប៉ះពាល់ពីគម្រោង ) ឬ នៅក្រៅតំបន់គម្រោងតាំងនៅ (និយតករ រដ្ឋាភិបាល តំណាងស្ថាប័នហិរញ្ញវត្ថុ ឬ ដៃគូវិនិយោគទុនផ្សេងៗ។)

ផែនការអភិវឌ្ឍន៍ជនជាតិភាគតិច(**Ethnic Minorities Development Plan**):ផែនការអភិវឌ្ឍន៍ជនជាតិភាគតិច មានអត្ថន័យដែលត្រូវបានផ្តល់ឱ្យវា ដោយអនុក្រិតស្តីពី សំណង និងការផ្លាស់ទីលំនៅរបស់ប្រជាជន ដែលរងផលប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍នានា [ដែលនឹងត្រូវធ្វើសេចក្តីព្រាងសម្រាប់ការពិចារណា] ។

ការវាយតម្លៃបរិស្ថាន: ជាដំណើរការ ដោយយោងតាម ច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង ច្បាប់ពាក់ព័ន្ធ ។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ: គឺជាការវាយតម្លៃយ៉ាងលំអិត ពីផលប៉ះពាល់ បរិស្ថាន និង សង្គម ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺ ជាដំណើរការសិក្សា និង ការប្រមើមើលពីផលប៉ះពាល់វិជ្ជមាន និង អវិជ្ជមាន លើបរិស្ថាន និង សង្គម ដើម្បីកំនត់ពីវិធានការការពារ និង កាត់បន្ថយផលប៉ះពាល់លើបរិស្ថាន និង សង្គម ដែលកើតចេញពីគម្រោង និង សកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ។

វិញ្ញាប័នបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន: គឺជាវិញ្ញាបនបត្រ ដែលចេញដោយ ក្រសួងបរិស្ថាន ដោយយោងតាមការវាយតម្លៃបរិស្ថានរបស់គម្រោង ដែលមានចែងលំអិតអំពីផែនការគ្រប់គ្រងបរិស្ថាន និង ល័ក្ខខ័ណ្ឌដែលចេញដោយក្រសួងបរិស្ថាន ។

ផែនការគ្រប់គ្រងបរិស្ថាន: សំដៅលើផែនការ ដែលមានចែងនៅក្នុង របាយការណ៍វាយ តម្លៃហេតុប៉ះពាល់បរិស្ថាន និង សង្គម ដែលបានកំនត់ពីវិធានការការពារ និង កាត់បន្ថយ ផលប៉ះពាល់ ការទទួលខុសត្រូវ និង កាលវិភាគសម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ផែនការតាមដាន និង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពីគម្រោង ដោយរួមបញ្ចូលទាំង ផែនការហិរញ្ញវត្ថុសម្រាប់ សកម្មភាពបរិស្ថានក្នុងតំណាក់កាលសាងសង់ ដំណើរការ និង ការបញ្ចប់គម្រោង ។

ប្រព័ន្ធគ្រប់គ្រងបរិស្ថាន (**Environmental Management System**) មានអត្ថន័យដែលត្រូវបានផ្តល់ឱ្យវាដោយស្តង់ដារនៃប្រព័ន្ធគ្រប់គ្រងបរិស្ថាន ISO 14001 នៃឆ្នាំ ២០០៤ ។

របាយការណ៍អង្កេតតាមដានបរិស្ថាន: ជារបាយការណ៍ស្តីពីការតាមដាន និង វាយតម្លៃបរិស្ថានរបស់គម្រោងអភិវឌ្ឍន៍ ដូចដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ដែលដាក់ជូនក្រសួងបរិស្ថាន ។ កម្មវិធីតាមដាន ត្រូវអនុវត្តតាមដំណើរការ និង ការកំនត់ពី គុណភាពបរិស្ថាន ដូចមានចែងក្នុង ផែនការគ្រប់គ្រងបរិស្ថាន ដែលបានអនុម័តជាផ្លូវការ ។

គម្រោងដែលមានស្រាប់: គម្រោងដែលមានស្រាប់ គឺ ជាគម្រោងទាំងឡាយណា ដែលកំពុងសាងសង់ ដំណើរការ ឬ នៅដំណាក់កាលបញ្ចប់នៃក្នុងវដ្តគម្រោង ដែលកំពុងអនុវត្តមុន ពេលចូលជាធរមានរបស់ច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

អ្នកត្រួតពិនិត្យឯករាជ្យ: ជាអ្នកត្រួតពិនិត្យជំនាញ ដែលមិនបានជួលមកដោយគម្រោង និង ពុំបានទទួលផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពីគម្រោង ។

ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីជ្រាបព័ត៌មានគ្រប់ជ្រុងជ្រោយ: មានន័យថា កិច្ចដំណើរការចូលរួមសាធារណៈត្រូវតម្រូវឱ្យម្ចាស់គម្រោងផ្តល់ព័ត៌មានដល់សហគន៍ អំពីវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន មុនពេលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម និងពេញលេញ ត្រូវបានបញ្ជូនទៅក្រសួងបរិស្ថាន។ ម្ចាស់គម្រោងត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ដល់សហគមន៍ដែលរងផលប៉ះពាល់ ក្នុងការពិចារណាលើវិធានការកាត់បន្ថយផលប៉ះពាល់នេះ ។ សហគមន៍ដែលរងផលប៉ះពាល់ត្រូវឯកភាពលើវិធានការណ៍កាត់បន្ថយផលប៉ះពាល់ ដោយពុំមានទទួលរងការដាក់សម្ពាធ ឬការបង្ខិតបង្ខំពីរូបវន្តបុគ្គល ឬនីតិបុគ្គលណាឡើយ ។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង: គឺជាការវាយតម្លៃហេតុប៉ះពាល់លើបរិស្ថាន និង សង្គមដំបូងដើម្បីប្រមើមើលផលប៉ះពាល់ផ្នែកបរិស្ថាន និង សង្គម ដែលកើតចេញពីគម្រោង និង សកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ដោយរំពឹងថានឹងមានផលប៉ះពាល់តិចបំផុត ដែលអាចមានវិធានការ កាត់បន្ថយផលប៉ះពាល់បរិស្ថាន ។

ផែនការគ្រប់គ្រង: ផែនការគ្រប់គ្រង គឺ ជាឧបករណ៍សម្រាប់ប្រើជាឯកសារគោលក្នុងការ គ្រប់គ្រង ជាពិសេស បញ្ហាគម្រោង និង ជាយន្តការសម្រាប់ដោះស្រាយទៅនឹងសំនួរ ហេតុអ្វី ជាអ្វី យ៉ាងម៉េច នរណា ប៉ុន្មាន និង ពេលណា សម្រាប់បញ្ហាទាំងនោះ ។

ប្រព័ន្ធគ្រប់គ្រង (**Management System**): ក្របខណ្ឌនៃដំណើរការ និងនីតិវិធីនានា ដែលត្រូវបានប្រើប្រាស់ក្នុងការធានាឱ្យបានថា អង្គការណា១អាចបំពេញកិច្ចការទាំងអស់ ដែលចាំបាច់តម្រូវឱ្យធ្វើ ដើម្បីសម្រេចបាននូវវត្ថុបំណងទាំងឡាយរបស់ខ្លួន។

ការកាត់បន្ថយ (**Offset**): ការអភិរក្សដែលអាចវាស់វែងបាន កើតពីសកម្មភាពដើម្បីបង្កើតអោយមានសំណងជំងឺចិត្តលើផលប៉ះពាល់លើជីវចំរុះ ដែលកើតចេញពីគម្រោងអភិវឌ្ឍន៍ និង យន្តការសមរម្យសម្រាប់ជៀសវាង កាត់បន្ថយ និង ការស្តារឡើងវិញ ។ ជាទូទៅ វាមិនស្ថិតនៅក្នុងទីតាំងរបស់គម្រោងទេ ។

ម្ចាស់គម្រោង: ម្ចាស់គម្រោង គឺជាម្ចាស់គម្រោង ឬ អ្នកអភិវឌ្ឍន៍គម្រោង ដែលសំដៅលើរូបវន្ត បុគ្គលទាំងឡាយ នីតិបុគ្គល ឬ ស្ថាប័ន ដែលបានទទួលការអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវ កសាង និង អនុវត្តគម្រោង ។ ម្ចាស់គម្រោង អាចមកពីស្ថាប័នឯកជន ស្ថាប័នរដ្ឋ ឬ ស្ថាប័នទទួលបន្ទុក អភិវឌ្ឍន៍ ។

ការចូលរួមជាសាធារណៈ: ការចូលរួមជាសាធារណៈ: មានន័យថា ជាការពិគ្រោះយោបល់ និង ការចូលរួមពិភាក្សាក្នុងដំណើរការ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការផ្លាស់ប្តូរគំនិត និង មតិយោបល់ ការទទួលយកព័តមានពីគ្រប់ភាគីដែលនឹងទទួលរងផលប៉ះពាល់ផ្ទាល់ និង ប្រយោល ពីគម្រោងអភិវឌ្ឍន៍ និង ដំណោះស្រាយបញ្ហា ដែលរាប់ចាប់តាំងពីកំឡុងពេលតាក់តែងផែនការ ការអនុវត្ត និង ការជួសជុលផ្នែកបរិស្ថាន និង ការស្តារឡើងវិញ មុនពេលបញ្ចប់គម្រោង ។

ការស្តារជាថ្មី (**Refurbishment**): ស្ថានភាពនៃការស្តារទៅកាន់ស្ថានភាពល្អរបស់វាកាលពីមុន។

គម្រោងផែនការផ្លាស់ទីលំនៅថ្មី (**Resettlement Action Plan**): ជាឯកសារ ឬ បណ្តុំឯកសារ ដែលធ្វើឡើងជាពិសេស ដើម្បីកំនត់សកម្មភាព ដែលនឹងយកមកប្រើដើម្បីជាដំណោះស្រាយបញ្ហា (ផែនការទាំងនេះនឹង កំនត់ដោយសេចក្តីណែនាំស្តីពី សំណងជំងឺ ចិត្ត និង ដំណោះស្រាយ សម្រាប់ប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍)។ ផែនការនេះ ត្រូវបញ្ចូលអត្តសញ្ញាណរបស់អ្នកដែល ត្រូវបានទទួលការដោះស្រាយ ការសិក្សាពីសង្គម-សេដ្ឋកិច្ច សម្រាប់អ្នកដែលទទួលការដោះស្រាយ វិធានការដែលនឹងយកមកអនុវត្ត ដែលជាផ្នែកមួយនៃដំណើរការដោះស្រាយ ដោយរាប់ទាំងជំនួយ នានា ក្នុងការដោះស្រាយបញ្ហា និង ការគាំទ្រផ្នែកជីវភាព ព្រមទាំងយន្តការផ្នែកច្បាប់ និង សំណងជំងឺចិត្ត តួនាទី និង ការទទួលខុសត្រូវរបស់ ស្ថាប័ន ការគ្រប់គ្រងថវិកា និង ហិរញ្ញវត្ថុ ពេលវេលា កម្មវត្ថុ និង ក្រុមគោលដៅ យន្តការកែប្រែទុក្ខព្រួយ ការតាមដានរបាយការណ៍ និង ការពិនិត្យ និង ការយល់ដឹងពីការពិគ្រោះយោបល់ ការចូលរួម និង ការផ្លាស់ប្តូរព័ត៌មាន ។

ការជ្រើសរើសគ្រោង: ការជ្រើសរើសគម្រោង មានន័យថា ជាការកំនត់ប្រភេទគម្រោងស្នើសុំ ដើម្បីពិនិត្យមើលថាតើ គម្រោងនោះចាំបាច់អោយធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ ការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

ការវាយតម្លៃហេតុប៉ះពាល់សង្គម: គឺជាដំណើរការនៃការសិក្សា និង ប្រមើមើលពី ផលប៉ះពាល់វិជ្ជមាន និង អវិជ្ជមាន លើផ្នែកសង្គមសេដ្ឋកិច្ចនៃសង្គមពីគម្រោង និង សកម្មភាព អភិវឌ្ឍន៍ដែលកំនត់ពីវិធានការសមរម្យដើម្បីទប់ស្កាត់ កាត់បន្ថយ និង ផ្តល់ជំងឺចិត្ត ដល់បុគ្គលដែល ទទួលរងការប៉ះពាល់ពីគម្រោង ដែលអាចជាផលប៉ះពាល់លើជីវិត ជីវភាព សុខុមាលភាព និង សុខភាព ។

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត: ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត សំដៅលើលំដាប់ ទ្រឹស្តីនៃការវិភាគ និង ការចូលរួម ដែលមានគោលបំណង ដើម្បីរួមបញ្ចូលការពិនិត្យពិច័យ ផ្នែកបរិស្ថាន ទៅក្នុងគោលនយោបាយ ផែនការ និង កម្មវិធីផ្សេងៗ និង ការវាយតម្លៃ ការពិនិត្យពិច័យ ទំនាក់ទំនងរវាងសេដ្ឋកិច្ច និង សង្គម ។

កិច្ចព្រមព្រៀងឆ្លងដែន: ជាកិច្ចព្រមព្រៀង ដែលបង្កើតឡើងដោយរដ្ឋត្រីភាគី ស្តីពី របៀបនៃការចែករំលែកធនធាន ដែលនឹងប្រើប្រាស់ដោយភាគីដែលពាក់ព័ន្ធ ហើយនឹងដំណើរការ ដែលត្រូវធ្វើប្រតិបត្តិតាម ដើម្បីរក្សាខ្លឹមសារនៃការព្រមព្រៀងនេះ ។

គម្រោងអភិវឌ្ឍន៍: សំដៅទៅលើគម្រោងអភិវឌ្ឍ គម្រោងវិនិយោគ សកម្មភាពអាជីវកម្ម និងសកម្មភាពទាំងឡាយផ្សេងទៀត ទាំងវិស័យឯកជន និងសាធារណៈ ។